សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# កំណែទម្រង់រដ្ឋបាលថ្នាក់ជាតិវិស័យថវិកា

ស្រាវជ្រាវចាប់ពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **ឆន ណារត្ន័**

**លឹម ស្រីលុច**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ទូរ សុខុម៉ា**


ថ្នាក់បរិញ្ញបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៤

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ជាបឋមយើងខ្ញុំ ឆន ណាគ្រី និង លឹម ស្រីលុច សូមលំឱនកាយក្រាបថ្វាយបង្គំដោយកិច្ចប្រណិប័តន៍ សម្តែងនូវកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតជូនលោកឳពុក អ្នកម្តាយ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាអប់រំទូន្មានប្រៀនប្រដៅឱ្យកូនបានសិក្សារៀនសូត្ររហូតទទួលបានជោគជ័យដូចសព្វថ្ងៃនេះ នេះជាគុណូបការៈជាអនេកប្បការ និងវិសេសវិសាលខ្ពង់ខ្ពស់ថ្លៃថ្លាបំផុតមិនអាចកាត់ថ្លៃបានរបស់លោកអ្នកមានគុណ ។

ទន្ទឹមគ្នានេះដែរ យើងខ្ញុំក៏សូមធ្វើការគោរព និងដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោក លោកស្រីសាស្រ្តាចារ្យ រួមទាំងលោកគ្រូអ្នកគ្រូដែលបម្រើការនៅបណ្ណាល័យ និងបុគ្គលិកអ្នកសម្របសម្រួលនានាទាំងអស់ ដែលបានគ្រប់គ្រងដឹកនាំសាកលវិទ្យាល័យ និងបានខិតខំប្រឹងប្រែងបំពេញកាតព្វកិច្ច តាមមុខងារ ដោយអស់ពីកម្លាំងកាយចិត្ត និង បញ្ញាស្មារតី ក្នុងគោលបំណងកសាងធនធានមនុស្សប្រកបទៅដោយសមត្ថភាពគ្រប់គ្រាន់ ពោលសំដៅដល់ធនធានមនុស្សដែលមានចំណេះដឹងខ្ពស់ មានក្រមសីលធម៌ គុណធម៌ ស្របតាមសេចក្តីត្រូវការរបស់សង្គមប្រជាជាតិ នាពេលបច្ចុប្បន្ន និងអនាគត។

ជាពិសេសសូមថ្លែងអំណរគុណចំពោះសាស្រ្តាចារ្យបណ្ឌិត **ទូរ សុខុម៉ា** ក្នុងការចំណាយពេលវេលាដ៏មានតម្លៃសម្រាប់ការណែនាំ តម្រង់ទិស សម្របសម្រួល និងផ្តល់ដំបូន្មានល្អៗដល់ក្រុមយើងខ្ញុំដែលជាមូលដ្ឋានគំនិតដ៏សំខាន់ក្នុងការសរសេរប្រធានបទមួយនេះឱ្យលេចចេញជារូបរាង។

ជាទីបញ្ចប់ យើងខ្ញុំសូមជូនស្នាដៃ និងគុណតម្លៃទាំងឡាយ ដែលបានទទួលពីការសិក្សាស្រាវជ្រាវមួយ នេះ ជូនចំពោះអស់លោកអ្នកដែលមានគុណ ដូចដែលយើងខ្ញុំបានរៀបរាប់ខាងលើ។ យើងខ្ញុំសូមប្តេជ្ញាចិត្តថានឹងយកនូវចំណេះដឹង បញ្ញាស្មារតី កម្លាំងកាយចិត្ត ដែលមានទៅជួយសង្គមកម្ពុជាមួយនេះឱ្យសមនឹងការតបស្នងជួយជ្រោមជ្រែងដ៏មានតម្លៃរបស់អ្នកទាំងអស់គ្នា ជាមួយគ្នានេះដែរក៏សូមប្រសិទ្ធពរជ័យជូនដល់អស់លោកលោកស្រីឱ្យទទួលនូវសុខសុភមង្គលទាំងផ្លូវកាយ និងផ្លូវចិត្តគ្រប់ពេលវេលាតរៀងទៅ។

# អារម្ភកថា

សារណាបញ្ចប់ការសិក្សាក្រោមប្រធានបទកំណែទម្រង់រដ្ឋបាលថ្នាក់ជាតិវិស័យថវិកា គឺជាប្រធានបទមួយដែលត្រូវបានស្រាវជ្រាវដោយយើងខ្ញុំ ឆន ណាគ្រី និង លឹម ស្រីលុច ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញរដ្ឋបាលសាធារណៈ ជំនាន់ទី១៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមការដឹកនាំរបស់បណ្ឌិត **ទូរ សុខុម៉ា**។

សារណាមួយនេះពិតជាមានសារៈសំខាន់បំផុតសម្រាប់និស្សិតរដ្ឋបាលសាធារណៈដូចជាយើងខ្ញុំក្នុងការសិក្សាឆ្វេងយល់ឱ្យកាន់តែស៊ីជម្រៅ និងចងក្រងទុកជាឯកសារ។ យើងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងក្នុងការចំណាយនូវកម្លាំងកាយចិត្ត ពេលវេលា និងធនធានផ្ទាល់ខ្លួនដើម្បីរៀបចំចងក្រងនូវកិច្ចការនៃសារណាមួយនេះឱ្យលេចចេញជារូបរាងឡើងព្រោះកិច្ចការមួយនេះបានធ្វើឱ្យយើងខ្ញុំចេះធ្វើការសិក្សាស្រាវជ្រាវយ៉ាងសកម្មដែលបានបង្កើននូវចំណេះដឹងមូលដ្ឋាន បណ្តុះគំនិតប្រាជ្ញា និងមានការយល់ដឹងកាន់តែច្បាស់អំពីប្រធានបទមួយនេះ។

យើងខ្ញុំសង្ឃឹម និងរំពឹងទុកជាមុនថា កិច្ចការមួយនេះនឹងអាចក្លាយជាប្រយោជន៍សម្រាប់មជ្ឈដ្ឋានអ្នកស្នេហាការសិក្សាទាំងឡាយ មិត្តនិស្សិត ក៏ដូចជាសិស្សានុសិស្សជំនាន់ក្រោយ ដោយចូលរួមក្នុងការបង្កើននូវពុទ្ធិ ចំណេះដឹងមូលដ្ឋានរបស់អ្នកគ្រប់គ្នា។ តាមរយៈសារណានេះដែរ ក៏អាចចូលរួមចំណែកក្នុងការផ្សព្វផ្សាយអំពីបេសកកម្ម តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ ព្រមទាំងស្នាដៃ និងសមិទ្ធផលដែលក្រសួងមុខងារសាធារណៈសម្រេចបាននាពេលកន្លងមក និងសមិទ្ធផលសំខាន់ៗពាក់ព័ន្ធនឹងការងារកែទម្រង់រដ្ឋបាលសាធារណៈ។

ដោយសារតែចំណេះដឹងនៅមានកម្រិត ដូច្នេះក្រុមយើងខ្ញុំជឿជាក់ថាកំហុសឆ្គងនៅតែកើតមានឡើងដោយជៀសពុំរួចនោះឡើយ ទាំងអត្ថន័យខ្លឹមសារ ពាក្យពេចន៍ឃ្លាឃ្លោង ទាំងអក្ខរាវិរុទ្ធ និងបច្ចេកទេសការចងក្រងនៅមានកម្រិតផងនោះ ។

អាស្រ័យហេតុនេះ យើងខ្ញុំសូមការខន្តីអភ័យទោសចំពោះកំហុសខុសឆ្គងដែលនឹងអាចកើតមានឡើងដោយប្រការណាមួយពីសំណាក់លោកគ្រូសាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ ហើយក៏រីករាយនឹងទទួលយកនូវការរិះគន់ដើម្បីជាទុនក្នុងការកែលម្អ និងធ្វើឱ្យការសិក្សាស្រាវលើកក្រោយមានភាពល្អប្រសើរឡើង។

ថ្ងៃច័ន្ទ ៣កើត ខែទុ.សាឍ ត្រីស័ក ពុទ្ធសករាជ ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២០

និស្សិតឈ្មោះ

ឆន ណាគ្រី　　　　លឹម ស្រីលុច

# មាតិកា

## សេចក្តីផ្តើម

ទំព័រ

១.លំនាំបញ្ហានៃការស្រាវជ្រាវ........................................................................................................១
២.ចំណោទបញ្ហានៃការស្រាវជ្រាវ.....................................................................................................២
៣.គោលបំណងនៃការស្រាវជ្រាវ.......................................................................................................២
៤.ទំហំ និងដែនកំណត់ នៃការស្រាវជ្រាវ..........................................................................................៣
៥.សារៈសំខាន់នៃការស្រាវជ្រាវ.......................................................................................................៣
៦.វិធីសាស្ត្រស្រាវជ្រាវ........................................................................................................................៤
៧.រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ.................................................................................................៥

## ជំពូកទី១

## ទម្រង់រដ្ឋបាលថ្នាក់ជាតិលើវិស័យថវិកា

១.១. កំណត់អត្ថន័យ..........................................................................................................................៦
១.២. បទដ្ឋានគតិយុត្ត..........................................................................................................................៧
១.២.១. ចំណាត់ថ្នាក់រដ្ឋបាលថ្នាក់ជាតិ...................................................................................៧
១.២.២. បទដ្ឋានផ្សេងៗជាប្រភពថវិកាថ្នាក់ជាតិ.........................................................................៧
១.៣. ប្រសិទ្ធភាពថវិកា........................................................................................................................១០
១.៣.១. នីតិវិធីគ្រប់គ្រងថវិកា.....................................................................................................១២
១.៣.២. ការប្រើប្រាស់ថវិកាក្នុងការអភិវឌ្ឍន៍.............................................................................១៣

## ជំពូកទី២

## ផ្នែកទី១

## ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

២.១. រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ជាតិ.......................................................................................................១៥
២.២.គោលនយោបាយហិរញ្ញវត្ថុសាធារណៈ.........................................................................................១៦
២.២.១. ចំណាយសរុបថវិកាថ្នាក់ជាតិ.........................................................................................១៨
២.២.២. កិច្ចលទ្ធកម្ម......................................................................................................................២០
២.៣. ការធ្វើវិចារណកម្មចំណាយថវិកាថ្នាក់ជាតិ.......................................................................................២២

២.៣.១. ចំណាយចរន្តថវិកាថ្នាក់ជាតិ..........................................................................២២
២.៣.២. ចំណាយមូលធនថ្នាក់ជាតិ..........................................................................២៤
២.៣.៣. ការជំរុញ និងពង្រីកប្រសិទ្ធភាពថវិកា..........................................................................២៥
២.៤. ទិសដៅ និងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ជាតិ..........................................................................២៦
២.៤.១. ការត្រួតពិនិត្យមើលលើការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ជាតិ..........................................................................២៨

## ផ្នែកទី២

## លទ្ធផល និងការវិភាគលើការអនុវត្ត

២.៥. លទ្ធផលកំណែទម្រង់ថវិកា..........................................................................៣៤
២.៥.១. លទ្ធផលកំណែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥..........................................................................៣៤
២.៥.២. លទ្ធផលកំណែទម្រង់ថ្នាក់ជាតិ..........................................................................៣៥
២.៦. វិភាគ..........................................................................៣៥
២.៦.១. ចំណុចខ្លាំង..........................................................................៣៥
២.៦.២. ចំណុចខ្វះខាត..........................................................................៣៦
សេចក្តីសន្និដ្ឋាន..........................................................................៣៧
អនុសាសន៍..........................................................................៣៩
ឯកសារពិគ្រោះ
ឧបសម្ព័ន្ធ

# សេចក្ដីផ្ដើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

យើងដឹងហើយថានាពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាជាប្រទេសមួយដែលកំពុងអភិវឌ្ឍ ហើយក៏ជាប្រទេសមួយដែលប្រកាន់យកការគ្រប់គ្រងប្រទេសបែបនីតិរដ្ឋផងដែរ ដូច្នេះហើយចំពោះការគ្រប់គ្រងឬបែងចែកថវិកាសម្រាប់ផ្គត់ផ្គង់ប្រទេសមួយគឺជារឿងសំខាន់បំផុតរបស់រាជរដ្ឋាភិបាលក៏ដូចជាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានតួនាទីក្នុងការរៀបចំថវិកាតាមប្រភេទតាមថ្នាក់ឲ្យបានសមស្រប។ យ៉ាងណាមិញការរៀបចំកញ្ចប់ថវិកាជាតិឬថវិការដ្ឋគឺចែកចេញជា ២ រួមមានថវិកាសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថវិកាថ្នាក់ក្រោមជាតិ។ ថវិកាថ្នាក់ជាតិសម្ដៅដល់ថវិការបស់ក្រសួងស្ថាប័នអង្គភាពសាធារណៈប្រហាក់ប្រហែល និងមន្ទីរជំនាញក្រោមឱវាទ ចំណែកថវិកាថ្នាក់ក្រោមជាតិសម្ដៅដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរួមមានរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំសង្កាត់។ ជាទូទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺមានច្បាប់នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុច្បាស់លាស់ ប៉ុន្តែវាក៏ចាំបាច់សម្រាប់ការធ្វើកំណែទម្រង់ថវិកា ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនានាដែលកើតមាន ក៏ដូចជាស្របទៅតាមបទដ្ឋានគតិយុត្តដែលបម្រើដល់សេវាសាធារណៈ។

ការកែទម្រង់នៃការប្រើប្រាស់ថវិកាថ្នាក់ជាតិឲ្យចំគោលដៅស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលគឺជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធគ្រប់គ្រងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យត្រូវបានបង្កើត និងដោះស្រាយ និងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងរបាយការណ៍ជាដើម កំពុងត្រូវបានអនុវត្ត និងកែលំអរជាបណ្ដើរៗ។ យុទ្ធសាស្ត្រពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គម ការលើកកំពស់សមភាពយេនឌ័របរិយាប័ន្ន និងសមធម៌សង្គមកំពុងត្រូវបានបញ្ជ្រាបឲ្យកាន់តែស៊ីជម្រៅទៅក្នុងរចនាសម្ព័ន្ធប្រព័ន្ធនិងនីតិវិធីបំពេញការងាររបស់រដ្ឋបាលថ្នាក់ជាតិ។ ក្របខ័ណ្ឌគោលនយោបាយនិង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការផ្ទេរមុខងារទៅឲ្យរដ្ឋបាលថ្នាក់ជាតិក៏ត្រូវបានដាក់ឲ្យអនុវត្តដែល ក្នុងនោះមុខងារមួយចំនួនក៏ត្រូវបានផ្ទេរជាបណ្ដើរៗឲ្យទៅរដ្ឋបាលថ្នាក់ជាតិទាំងក្នុងផែននៃការប្រគល់ និងការធ្វើប្រតិភូកម្មក្នុងលក្ខណៈជាការអនុវត្តសាកល្បងផងដែរ។ ចំពោះសកម្មភាពជាច្រើននៃការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ជាតិក៏ត្រូវបានអនុវត្តដោយផ្អែកតាមតម្រូវការជាក់ស្ដែង ដើម្បីគាំទ្រដល់ការអភិវឌ្ឍផ្លាស់ប្ដូរនៃកិច្ចដំណើរការកែទម្រង់នេះ។

ទោះបីជាសម្រេចនូវសមិទ្ធផលជាគន្លឹះៗយ៉ាងនេះក្ដីក៏នៅមានភាពស្មុគស្មាញ ដោយសារតែកំណែទម្រង់នេះមានការពាក់ព័ន្ធទៅនឹងស្ថាប័ននានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលមានចរិតលក្ខណៈខុសៗគ្នាព្រមទាំងមានកិច្ចការជាអាទិភាពជាច្រើនផ្សេងទៀត ដែលត្រូវបន្តអនុវត្តជាពិសេសលើការពង្រឹងអភិបាលនុក្រម និងសមត្ថភាពស្ថាប័ន។ ទោះបីជាយើងមានបទដ្ឋានគតិយុត្តជាច្រើនទាក់ទងនឹងកំណែទម្រង់ថវិកានេះយ៉ាងណាក៏ដោយក៏នៅមិនទាន់ឈានដល់គោលដៅដែលរដ្ឋ ឬរាជរដ្ឋាភិបាលចង់បាន ដូច្នេះហើយគឺត្រូវស្វែងរកយុទ្ធសាស្ត្រផ្សេងដើម្បីកែទម្រង់ប្រព័ន្ធថវិកានេះឲ្យកាន់តែប្រសើរឡើង។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ដូចដែលបានបង្ហាញជូនអំពីលំនាំបញ្ហាខាងលើយើងមើលឃើញថា រាជរដ្ឋភិបាលកម្ពុជានៅតែមានបញ្ហាទាក់ទងនឹងការប្រើប្រាស់ ឬការចាយវាយកញ្ចប់ថវិការដ្ឋបាលថ្នាក់ជាតិនៅមិនទាន់ចំគោលដៅ ឬមិនទាន់មានប្រសិទ្ធភាពខ្ពស់នៅឡើយ។ កំណែទម្រង់រដ្ឋបាលថ្នាក់ជាតិលើវិស័យថវិកា គឺជាដំណើរការនៃការគ្រប់គ្រងផ្លាស់ប្តូរកែប្រែនូវទម្រង់ចាស់មួយចំនួនដែលផ្ទុកតម្លៃអវិជ្ជមានឱ្យក្លាយជាទម្រង់ថ្មីមួយ ដែលមានការជ្រើសរើសនូវវិធីសាស្ត្រដែលល្អជាងគេ ត្រឹមត្រូវជាងគេ មានការគាំទ្រជាងគេ និងក្តីរំពឹងថានឹងទទួលបាននូវលទ្ធផលជោគជ័យជាងគេ។ គោលនយោបាយកំណែទម្រង់ស៊ីជម្រៅដែលរាជរដ្ឋាភិបាលបានបន្តអនុវត្តធ្វើឱ្យស្ថានភាពថវិការដ្ឋបាលថ្នាក់ជាតិមានការកែប្រែឈានទៅមុខដោយគោលដៅដែលបានដាក់ចេញ សុទ្ធតែបានផ្តោតលើគុណភាព និងប្រសិទ្ធភាពនៃសេវាសាធារណៈដែលត្រូវបម្រើប្រជាពលរដ្ឋឱ្យបានល្អប្រសើរ។ ទោះបីជារាជរដ្ឋាភិបាលបានដាក់ចេញនូវគោលដៅយ៉ាងច្បាស់លាស់បែបនេះក៏ដោយ ក៏មិនមែនមានន័យថាគ្រប់សកម្មភាពដែលបានដាក់ចេញសម្រាប់ការអនុវត្តនោះ បានធ្វើឱ្យមន្ត្រីក្រោមឱវាទយល់ច្បាស់ហើយយកទៅអនុវត្តបានល្អតាមក្តីរំពឹងទុកនោះដែរ ជារួមគឺអាស្រ័យលើកម្រិតសមត្ថភាពយល់ដឹងរបស់អ្នកដែលមានចំណែកពាក់ព័ន្ធសំខាន់ៗ រួមជាមួយការប្តេជ្ញាចិត្តក្នុងការអនុវត្តឱ្យសម្រេចបានជោគជ័យ។ ហេតុនេះដើម្បីដឹងថាបញ្ហាប្រឈមនានាត្រូវបានដោះស្រាយ ឬយ៉ាងណា យើងខ្ញុំបានកំណត់នូវចំណោទបញ្ហានៃការស្រាវជ្រាវចំនួនពីរ គឺ៖

១. តើអ្វីទៅជាបញ្ហាប្រឈមដែលនាំឲ្យការអនុវត្តប្រព័ន្ធថវិកានៅរដ្ឋបាលថ្នាក់ជាតិមិនមានប្រសិទ្ធភាព ឬប្រសិទ្ធភាពនៅមានកម្រិតបែបនេះ ?

២.តើត្រូវធ្វើដូចម្តេចដើម្បីឲ្យការអនុវត្តកំណែទម្រង់ថវិការដ្ឋបាលថ្នាក់ជាតិនៅព្រះរាជាណាចក្រកម្ពុជាឲ្យកាន់តែមានប្រសិទ្ធភាព ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

ដូចដែលបានចោទឡើងក្នុងចំណុចទី២រួចហើយ មានបញ្ហាប្រឈមមួយចំនួនទាមទារនូវដំណោះស្រាយដ៏ប្រសើរមួយដូចនេះប្រធានបទ កំណែទម្រង់រដ្ឋបាលថ្នាក់ជាតិលើវិស័យថវិកា នៃការស្រាវជ្រាវនេះត្រូវតែបានស្វែងចេញនូវគោលបំណងសំខាន់ៗដែលមានពាក់ព័ន្ធនឹងក្របខណ្ឌនៃការស្រាវជ្រាវដូចតទៅ៖

-សិក្សាពីការវិវត្តនៃរដ្ឋបាលសាធារណៈក្នុងប្រទេសកម្ពុជា

-សិក្សាស្វែងយល់ពីចំណុចអទិភាពក្នុងការធ្វើការកំណែទម្រង់

-សិក្សាពីរដ្ឋបាលថ្នាក់ជាតិក្នុងវិស័យថវិកា

-ស្វែងរកដំណោះស្រាយដែលរដ្ឋាភិបាលបានអនុវត្តកន្លងមក

ដើម្បីជាមូលដ្ឋានក្នុងការពិចារណា និងផ្តល់អនុសាសន៍សមស្របណាមួយតាមកម្រិតនៃការយល់ដឹង។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានវិសាលភាពលើ (១) ការងារកែទម្រង់រដ្ឋបាលថ្នាក់ជាតិវិស័យថវិកាស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រសួងមុខងារសាធារណៈ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (២) កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈដែលរដ្ឋាភិបាលកម្ពុជាបាននិងកំពុងអភិវឌ្ឍនាពេលបច្ចុប្បន្ន (៣)ច្បាប់ និងបទ
ដ្ឋានគតិយុត្តពាក់ព័ន្ធនានាដែលក្រសួងមុខងារសាធារណៈ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈដាក់ចេញដើម្បីសម្រួលដល់ការអនុវត្ត។ ខ្លឹមសារនៃប្រធានបទនេះជាប់ទាក់ទិននឹង៖

ទី១: យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព រៀបចំដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងជំពូកទី៣ យុទ្ធសាស្ត្រនៃការទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ គឺដំណើរការការរៀបចំថវិកាប្រចាំឆ្នាំ ផែនការយុទ្ធ សាស្ត្រ ការអនុវត្ត និងត្រួតពិនិត្យថវិកា និងកិច្ចលទ្ធកម្មផងដែរ។

ទី២: ច្បាប់ និងបទបញ្ញត្តិ និងថវិកាឆ្នាំ២០២១ ដែលមានសារាចរណ៍ណែនាំស្តីពីការអនុវត្តថវិកាឆ្នាំ២០២១ អនុក្រឹតលេខ២១៦ អនក្រ.បកចុះថ្ងៃអង្គារ ១៥កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការបែងចែកឥនទានចំណូលថវិកាជាតិតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ។

ទី៣: កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៩-២០៣០ នៃក្រសួងមុខងារសាធារណៈបានកំណត់កម្មវិធីសំខាន់ៗដើម្បីឲ្យកំណែទម្រង់មានវិសាលភាពលើ ចក្ខុវិស័យ គោលបំណង គោលដៅ យុទ្ធសាស្ត្រ ក្របខណ្ឌពេលវេលាការរៀបចំ និងការអនុវត្តកម្មវិធីជាតិ យន្តការស្ថាប័នសម្រាប់ការអនុវត្ត ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តកម្មវិធីជាតិ និងប្រភពធនធាន គោលការណ៍លើកទឹកចិត្ត។

ទី៤: ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ២០២០ បានសិក្សាក្នុងជំពូកទី១ ថវិកាថ្នាក់ជាតិដែលបានប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិនូវពន្ធដា វិភាគទាន អាករ ផលទុន និងចំណូលនានា ព្រមទាំងមានការបែងចែកថវិកាដូចជា ចំណូលចរន្ត ចំណូលមូលធន ចំណូលមូលធនក្នុងស្រុក ចំណូលមូលធនក្រៅស្រុក និងឥទានចំណាយថវិកាថ្នាក់ជាតិ មានចំណាយចរន្ត ចំណាយមូលធន ។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះយើងខ្ញុំផ្ទាល់ កិច្ចការមួយនេះបានពង្រឹង និងពង្រីកចំណេះដឹង និងទទួលបទពិសោធន៍តាមរយៈការប្រមូលផ្តុំឯកសារដែលស្តែងចេញតាមរូបភាពជាច្រើន គោលបំណងទទួលបានព័ត៌មានច្បាស់លាស់ និងជាក់ស្តែង។ ជាមួយគ្នាផងដែរការស្រាវជ្រាវមួយនេះបានផ្តល់នូវពុទ្ធិតាមរយៈការស្វះស្វែងទាញយកប្រភពព័ត៌មាន និងដកស្រង់នូវខ្លឹមសារល្អៗដែលទាក់ទងទៅនឹងការកែទម្រង់រដ្ឋបាលថ្នាក់ជាតិវិស័យថវិកាពីប្រភពលិខិតបទដ្ឋានគតិយុត្តនានា ក៏ដូចជាសម្រង់ប្រសាសន៍ដ៏មានតម្លៃរបស់ថ្នាក់ដឹកនាំសំខាន់ៗ។ ជាពិសេសកិច្ចការមួយនេះអាចឱ្យយើងខ្ញុំបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដោយជោគជ័យ។

ទន្ទឹមនឹងនេះដែរកិច្ចការមួយនេះ ក៏អាចចូលរួមចំណែកក្នុងផ្សព្វផ្សាយអំពីបេសកកម្ម តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធព្រមទាំងស្នាដៃ និងសមិទ្ធផលដែលក្រសួងមុខងារសាធារណៈជាសេនាធិការរបស់រាជរដ្ឋាភិបាល

សម្រេចបាននាពេលកន្លងមក រួមជាមួយសមិទ្ធិផលដែលសំខាន់ៗពាក់ព័ន្ធនិងការងារកែទម្រង់រដ្ឋបាលសាធារណៈ ដល់សាធារណៈជនឲ្យបានដឹង។

ក្តោបជារួមការស្រាវជ្រាវនូវប្រធានបទមួយនេះ ផ្តល់នូវសារៈសំខាន់ចំពោះ៖

- ស្ថាប័នរដ្ឋបាលថ្នាក់ជាតិ ដែលជួយជម្រុញឲ្យការប្រើប្រាស់ថវិកាឲ្យចំគោលដៅ និងមានប្រសិទ្ធភាព
- ប្រជាពលរដ្ឋទូទៅ បានដឹងពីគម្រោងនៃកញ្ចប់ថវិកា ឬចំណូល-ចំណាយសម្រាប់ថ្នាក់ជាតិ ថ្នាក់ក្រោមរបស់រាជរដ្ឋាភិបាល
- សម្រាប់យើងខ្ញុំទាំងពីរនាក់ផ្ទាល់ គឺទទួលបាលនូវចំណេះដឹងដ៏ប្រពៃសម្រាប់សារណាមួយនេះ ព្រោះបានបង្ហាញឲ្យឃើញពីរបៀបរបបនៃការគ្រប់គ្រង និងការបែងចែកថវិកាដ៏មានប្រសិទ្ធភាពរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មួយវិញទៀតបានធ្វើឲ្យយើងខ្ញុំទាំងពីរនាក់បាន បញ្ចប់ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈដ៏ជោគជ័យ។

## ៦.វិធីសាស្ត្រនៃស្រាវជ្រាវ

កិច្ចការស្រាវជ្រាវមួយនេះ ត្រូវបានរៀបចំឡើងដោយមានការសិក្សា ប្រមូលទិន្នន័យបានច្បាស់លាស់ និងត្រឹមត្រូវ ព្រមទាំងបានឆ្លងកាត់នូវការវិភាគលើទិន្នន័យ និងលទ្ធផលដែលទទួលបាន។

**ក. ទិន្នន័យចម្បង**

ជាប្រភេទទិន្នន័យដែលទទួលបានតាមរយៈការចុះកម្មសិក្សាសុំឯកសារពី បណ្ណារក្ស នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងទទួលបានការណែនាំពីសាស្ត្រចារ្យបណ្ឌិត ទូរ សុខុម៉ា អំពីចំណុចដែលត្រូវស្រាវជ្រាវ និងចុះកម្មសិក្សាចំនួនពីរដង ជាមួយ កញ្ញា មោង រីណា ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃគណៈកម្មាធិការជាតិនៃសមាគមច្បាប់អាស៊ានកម្ពុជា។

**ខ. ទិន្នន័យបន្ទាប់បន្សំ**

ជាប្រភេទទិន្នន័យដែលទទួលបានតាមរយៈ បណ្ណាល័យ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចការស្វែងយល់ពីបណ្ណាឯកសារនានានិងលិខិតបទដ្ឋាន គតិយុត្តដែលពាក់ព័ន្ធ ដូចជាច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសកម្មវិធី កំណែទម្រង់យុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រសួងមុខងារសាធារណៈ។ល។

**គ. ការវិភាគទិន្នន័យ**

បន្ទាប់ពីទទួលបានទិន្នន័យរួចមក យើងខ្ញុំបានវិភាគលើទិន្នន័យដោយធ្វើការប្រៀបធៀបរវាងទ្រឹស្តីដែលបានដាក់ចេញ និងការអនុវត្តជាក់ស្តែងលើការងារកែទម្រង់រដ្ឋបាលវិស័យថវិកានេះ ដើម្បីសិក្សារកចំណុចខ្លាំង និងចំណុចខ្វះខាតឆ្ពោះទៅរកការសន្និដ្ឋានរួម ព្រមទាំងចូលរួមផ្តល់ជាអនុសាសន៍តាមលទ្ធភាពដែលអាចធ្វើបានដើម្បីកែលម្អនូវចំណុចខ្វះខាតឱ្យកាន់តែល្អប្រសើរជាងមុន។

## ៧.រចនាសម្ព័ន្ធនៃស្រាវជ្រាវ

ក្រោយពីបានពិភាក្សាគ្នា និងការស្វែងរកនូវប្រភពឯកសារពាក់ព័ន្ធនានា ព្រមទាំងទទួលបាននូវការណែនាំ និងឯកភាពពីសាស្ត្រាចារ្យណែនាំរួចមក យើងខ្ញុំបានសម្រេចបែងចែករចនាសម្ព័ន្ធនៃការស្រាវជ្រាវ ដូចខាងក្រោម៖

សេចក្តីផ្តើម៖ ដែលឃរិយាយអំពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ និងវិសាលភាពនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី១ ទ្រឹស្តីទម្រង់រដ្ឋបាលថ្នាក់ជាតិវិស័យថវិកា:** បានបង្ហាញពីទ្រឹស្តី ច្បាប់ហិរញ្ញវត្ថុ ច្បាប់ថវិកា និងបទបញ្ញត្តិ នីតិវិធីសម្រាប់គ្រប់គ្រងថវិកាថ្នាក់ជាតិស្របតាមគោលនយោបាយរបស់រដ្ឋាភិបាល។

**ជំពូក២ ផ្នែកទី១ ការរៀបចំយុទ្ធសាស្ត្រថវិកា:** ក្នុងជំពូកនេះបានធ្វើការបង្ហាញពីយុទ្ធសាស្ត្រ និងទិសដៅ ដែលបានកំណត់ក្នុងកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ វដ្តថវិកាការធ្វើផែនការយុទ្ធសាស្ត្រ ការរៀបចំថវិកា ការចរចា និងអនុម័តថវិកា ព្រមទាំងការតាមដានវាយតម្លៃលើការរៀបចំយុទ្ធសាស្ត្រ។

**ជំពូកទី២ ផ្នែកទី២ លទ្ធផល និងការវិភាគលើការកែទម្រង់រដ្ឋបាលសាធារណៈលើវិស័យថវិកា:** ក្នុងផ្នែកនេះបានធ្វើការបង្ហាញនីវលទ្ធផលនៃការអនុវត្តនិងការវិភាគលើប្រធានបទទាំងមូលដែលជាទម្លាំករណ៍ក្នុងការបកស្រាយដើម្បីចែករំលែកជាចំណេះដឹងក្នុងការស្រាវជ្រាវ ដោយផ្តោតសំខាន់លើចំណុចទាំង២ជំពូក។

**សេចក្តីសន្និដ្ឋាន:** តាមរយៈការស្រាវជ្រាវខាងលើ រាជរដ្ឋាភិបាលមានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងក្រសួងមុខងារសាធារណៈបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ដោយដាក់ចេញនូវគោលបំណង គោលដៅ យុទ្ធសាស្ត្រ និងសកម្មភាពយ៉ាងច្បាស់លាស់ តាមរយៈការជំរុញតាមដាន និងសហការជាមួយក្រសួងស្ថាប័ននានារួមជាមួយដៃគូអភិវឌ្ឍ ការខិតខំនេះសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្តព្រោះសកម្មភាពទាំងឡាយដែលបានដាក់ចេញ សុទ្ធតែបានបំពេញទោះបីជាមានសកម្មភាពខ្លះសម្រេចបានដោយផ្នែកក៏ដោយ។

# ជំពូក១

# ទម្រង់រដ្ឋបាលថ្នាក់ជាតិលើវិស័យថវិកា

## ១.១. កំណត់អត្ថន័យ

ពាក្យ រដ្ឋបាល ន័យអក្សរសាស្ត្របានមកពី រដ្ឋ និងអភិបាល រដ្ឋ មានន័យថា ដែន ឬប្រទេស ចំណែងអភិបាលមានន័យថា អ្នកគ្រប់គ្រង អ្នកបីបាច់ថែរក្សា អ្នកថែរក្សា។ ដូច្នេះរដ្ឋបាលមានន័យថា អ្នករក្សាដែន ឬប្រទេស ។[១]

ពាក្យ រដ្ឋបាលន័យទូលាយបែបបច្ចេកទេសត្រូវបានគេយល់គ្រប់គ្នាថាជាសកម្មភាព ឬជាការគ្រប់គ្រងរដ្ឋព្រោះជួនកាលគេប្រើជាសកម្មភាពជួនកាលជាលក្ខណៈអង្គការ ហើយថែមទាំងប្រើបាន ទៅលើវិស័យឯកជន និងវិស័យសាធារណៈទៀតផង។

ន័យចង្អៀតបែបបច្ចេកទេសៈ ពាក្យ រដ្ឋបាល សំដៅលើ រដ្ឋបាលសាធារណៈ។ យើងអាចប្រើពាក្យថា រដ្ឋការ ឬរាជការ ដែលមិននាំឱ្យមានការភ័ន្តច្រឡំជាមួយពាក្យ រដ្ឋបាល ក្នុងវិស័យឯកជននោះទេ។

រដ្ឋបាលសាធារណៈគឺជាវិស័យសិក្សាស្រាវជ្រាវ ដែលមានគោលបំណងជាសំខាន់ ធ្វើឱ្យរាជរដ្ឋាភិបាល អាចដំណើរការបាន តាមរយៈការធ្វើឱ្យរីកចម្រើនលើការគ្រប់គ្រង និងគោលនយោបាយ ក្រៅពីនេះមានការផ្តល់និយមន័យរដ្ឋបាលផ្សេងៗជាច្រើនទៀត។

ពាក្យថវិកាជាតិ គឺជារបាយការណ៍របស់រដ្ឋាភិបាលក្នុងការគ្រោងប្រមូលចំណូល និងចំណាយ ហើយអនុញ្ញាតិឱ្យរដ្ឋាភិបាលកំណត់ថា តើខ្លួនមានប្រាក់គ្រប់គ្រាន់ ឬទេសម្រាប់ការចំណាយ។ ថវិកាជាតិផ្តល់សិទ្ធិអំណាចឱ្យអង្គនីតិប្រតិបត្តិក្នុងការប្រមូលចំណូល និងការអនុវត្តចំណាយដើម្បីឱ្យបាននូវគោលដៅរបស់ខ្លួនក្នុងការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍសេដ្ឋកិច្ច។

---

[១] វចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត

កំណែទម្រង់រដ្ឋបាលវិស័យថវិកា ជាការសិក្សាស្រាវជ្រាវដែលមានគោលបំណងជាសំខាន់ធ្វើឱ្យរាជរដ្ឋាភិបាលអាចដំណើរការបានតាមរយៈការធ្វើឱ្យរីកចម្រើនលើការគ្រោងចំណូលចំណាយ ដែលរាជរដ្ឋាភិបាលបានកំណត់ ហើយការអនុវត្តរបស់ខ្លួនចំគោលដៅ ឬយ៉ាងណា។

## ១.២. បទដ្ឋានគតិយុត្ត

### ១.២.១. ចំណាត់ថ្នាក់រដ្ឋបាលថ្នាក់ជាតិ

ចំណាត់ថ្នាក់កម្មវិធីរដ្ឋបាលថ្នាក់ជាតិត្រូវបានដាក់ឱ្យអនុវត្តចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិដូចមានចែងក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសនេះ។ អគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចរៀបចំបង្កើតបន្ថែមនៃលេខកូត ចំណាត់ថ្នាក់ កម្មវិធី តាមតម្រូវការចាំបាច់សម្រាប់ការអនុវត្តថវិកាប្រចាំឆ្នាំ នៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយនៅចុងឆ្នាំនីមួយៗត្រូវរៀបចំប្រកាសបំពេញបន្ថែមលេខកូតចំណាត់ ថ្នាក់កម្មវិធីដែលបានបង្កើតបន្ថែមដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យ និងចុះហត្ថលេខាលើប្រកាសបំពេញបន្ថែម។[២]

### ១.២.២. បទដ្ឋានផ្សេងជាប្រភពថវិកាថ្នាក់ជាតិ

#### ក. ច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈ

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ មានគោលដៅកំណត់គោលការណ៍សំខាន់ជាមូលដ្ឋានសម្រាប់គ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈទាំងមូល និងសម្រាប់រៀបចំច្បាប់ហិរញ្ញវត្ថុ។

រដ្ឋបាលថ្នាក់ជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ក្រោមជាតិ បុគ្គលិកដែលជាមន្ត្រីសាធារណៈ និងប្រត្តិបត្តិករនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈទាំងមូល ត្រូវប្រកាន់ភ្ជាប់នូវមូលដ្ឋាននៃគោលការណ៍បូរណភាព សមាគតភាព សង្គតិភាព គណនេយ្យភាព តម្លាភាព និងភាពគ្រប់ជ្រុងជ្រោយព្រមទាំងវិសាលភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល និងគោលការណ៍គន្លឹះទាំង១១យ៉ាងនៃថវិកា។ ថវិការៀបចំទៅតាមចំណាត់ថ្នាក់រដ្ឋបាលដែលផ្អែកលើរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលចំណាត់ថ្នាក់សេដ្ឋកិច្ចដែលផ្អែកលើប្រភេទចំណាយ ចំណាត់ថ្នាក់មុខងារដែលផ្អែកលើគោលបំណង និងចំណាត់ថ្នាក់តាមកម្មវិធី។ ការផ្ទេរឥណទានពីក្រសួង-ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែលមួយទៅមួយទៀត កំណត់ដោយច្បាប់ហិរញ្ញវត្ថុ។ ប៉ុន្តែការផ្ទេរឥណទានពីក្រសួង-ស្ថាប័ន ឬពីអង្គភាពសាធារណៈប្រហាក់ប្រហែលមួយទៅមួយទៀតដោយភាពចាំបាច់នៃការងារពង្រឹងរចនាសម្ព័ន្ធ ឬរដ្ឋបាលរបស់រដ្ឋាភិបាលអាចប្រព្រឹត្តទៅបានដោយ អនុក្រឹតក្នុងករណីការផ្ទេរឥណទាននេះ មិនកែប្រែមុខចំណាយ និងការបែងចែកឥណទានតាមជំពូកនីមួយៗទេ។[៣]

#### ខ. ច្បាប់ថវិកា

[២] ប្រកាសស្តីពីការបំពេញឲ្យអនុវត្តចំណាត់ថ្នាក់គម្រោងនៃមាតិកាថវិកា ប្រកាសលេខ៨៨២ សហវ-ប្រក ចុះថ្ងៃទី០៧ កញ្ញា ឆ្នាំ២០១៧

[៣] ច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២០ មាត្រា៦ មាត្រា១២ និងមាត្រា៥៥

ស្ថិតក្រោមអំណាចនៃនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំគម្រោងថវិកាដាក់ជូនរដ្ឋាភិបាលពិនិត្យក្នុងលក្ខខណ្ឌដាក់កំណត់ដូចតទៅះ

រៀងរាល់ឆ្នាំនៅខែមីនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំទស្សនៈវិស័យនៃថវិកាឆ្នាំបន្ទាប់ ដោយឆ្លងកាត់តាមកាលវិភាគនៃស្ថានការណ៍សេដ្ឋកិច្ច និងហិរញ្ញវត្ថុសមត្ថកម្មទាំងឡាយនៃការវិវត្តន៍នៃស្ថានភាពក្នុងរយៈពេលខ្លី និងរយៈពេលមធ្យម និងការរៀបចំសង្កត់នៃម៉ាក្រូសេដ្ឋកិច្ចដែលអាចកើតមាន។

នៅក្នុងក្របខណ្ឌនេះ រដ្ឋាភិបាលកំណត់នូវអាទិភាពជាតិ និងការជ្រើសរើសដោយសមស្រប។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបង្កើតលើមូលដ្ឋានទាំងនេះនូវចំនួនសរុបនៃគម្រោងថវិកា ចែកចេញជាចំណូល និងជាចំណាយ និងរៀបចំសេចក្តីព្រៀងដំបូងនៃថវិកាដែលមានលក្ខណៈជារួម ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រី។

សេចក្តីព្រៀងដំបូងនៃថវិកា បានអនុម័តពីរាជរដ្ឋាភិបាលក្រោមរូបភាពជាទិសដៅដែលកំណត់នូវលក្ខខណ្ឌទាំងឡាយជាកំណត់ក្នុងនោះត្រូវរៀបចំសំណើរថវិកាសម្រាប់ឆ្នាំ បន្ទាប់មកវិភាគទិន្នន័យសំខាន់ៗនៃស្ថានការណ៍សេដ្ឋកិច្ចជាទូទៅ និងផលវិបាកដែលអាចកើតមានដើម្បីធានាតុល្យភាពជាគោលសំខាន់ និងកំណត់ចំនួននៃថវិកាសរុបតាមក្រសួង ឬអង្គការប្រហាក់ប្រហែល និងតាមប្រភេទចំណាយទាំងឡាយ។

ព្រមជាមួយគ្នា រដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំ និងផ្ញើជូនរដ្ឋអំណាចទាំងឡាយនូវសារាចរថវិកាមានលក្ខណៈជាបច្ចេកទេសបញ្ជាក់ពីបែបបទនៃការបង្កើតគម្រោង ពីវិធីវាយតម្លៃដែលត្រូវអនុវត្តពីការបង្ហាញជូនសម្រាប់អនុម័ត និងឯកសារយុត្តិការដែលត្រូវផ្តល់ជូន។

រដ្ឋមន្ត្រីគ្រប់ក្រសួង នាយកគ្រប់ស្ថាប័នរដ្ឋបាលបង្កើតគម្រោងចំណាយ-ចំណូល ជាកំណត់របស់ខ្លួនសម្រាប់រដ្ឋអំណាចកណ្តាល សម្រាប់អង្គភាពខាងក្រៅទាំងឡាយរបស់ខ្លួននៅតាមខេត្តនានា និងអង្គភាពក្រោមឱវាទ។ គម្រោងទាំងនេះត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅខែកញ្ញា។

នៅខែកញ្ញាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រមូលផ្តុំគ្រប់សំណើរចំណាយ ពិនិត្យ និងពិភាក្សាជាមួយរដ្ឋមន្ត្រីពាក់ព័ន្ធ ធ្វើការកែតម្រូវនូវអ្វីចាំបាច់ស្របតាមបញ្ញត្តិនៃការណែនាំថវិកា និងបន្ថែមលើគម្រោងចំណូលនូវអ្វីចាំបាច់ទាំងនេះ។

នៅខែវិច្ឆិកា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កសាងនូវគម្រោងច្បាប់ហិរញ្ញវត្ថុដែលពិនិត្យ និងយល់ព្រមពីរាជរដ្ឋាភិបាល ហើយដាក់ជូនសភាជាតិនៅខែធ្នូ ដើម្បីពិភាក្សា និងអនុម័ត មុនថ្ងៃទី២៥ ខែធ្នូ។[៤]

**គ.ច្បាប់កែតម្រូវ**

ប្រការ១. ត្រូវបានដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលចែកជាចំណាត់ថ្នាក់ចំណូល ចំណាយ និងត្រូវបានបែងចែក ជាក្រុម ប្រភេទ ជំពូក គណនី និងអនុគណនី ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ ភ្ជាប់ជាមួយប្រកាសនេះ។

[៤] ច្បាប់ថវិកា ឆ្នាំ២០២១ មាត្រា១ និងមាត្រា៣

(ឧបសម្ព័ន្ធទី២)មាតិកាចំណាយថវិកា ជំពូកគណនីអនុគណនីបរិយាយពីសរុបរួមចំណាយថវិកា(ក+ខ) គឺសរុបចំណាយចរន្ត និងសរុបចំណាយមូលធន។ សរុបចំណាយចរន្ត(ក្រុមទី១+ក្រុមទី២) ជាចំណាយប្រចាំខែ ដែលប្រមូលផ្តុំនូវគណនីទាំងឡាយសម្រាប់កត់ត្រារាល់បន្ទុកតាមប្រភេទនីមួយៗ ក្នុងនោះមានៈ ចំណាយពិត ចំណាយតាមដីកា និងចំណាយមិនបានគ្រោងទុក។ ក្រុមទី១ចំណាយពិត (ប្រភេទទី១+ ប្រភេទទី២+ ប្រភេទី៣+ប្រភេទទី៤) ចំណាយជាសាច់ប្រាក់ជាក់ស្តែងក្នុងនោះរួមមានៈ ចំណាយមធ្យោបាយសេវាបន្ទុក ហិរញ្ញវត្ថុ អន្តរាគមន៍សាធារណៈ ចំណាយផ្សេងៗ និងការសង និងបង្វិលវិញ។

(ឧបសម្ព័ន្ធទី១)មាតិកាចំណូលថវិកាជំពូកគណនីអនុគណនី ឈ្មោះគណនីសរុបរួមចំណូលថវិកា (ក+ខ)គឺសរុបចំណូលចរន្ត និងសរុបចំណូលមូលធន។ សរុបចំណូលចរន្ត(ក្រុមទី១+ក្រុមទី២) ចំណូលដែលត្រូវប្រមូលជាប្រចាំ ចំណូលនេះរួមមានចំណូលពិត និងចំណូលតាមដីកា។ ក្រុមទី១(ប្រភេទទី១+ប្រភេទទី២) ចំណូលពិតជាសាច់ប្រាក់ជាក់ស្តែង ចំណូលនេះរួមមានចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ ប្រភេទទី១ ចំណូលសារពើពន្ធ គឺជាពន្ធអាករ និងសិទ្ធិដែលត្រូវបានបង្វែរជាកាតព្វកិច្ចទៅឱ្យរដ្ឋ។ ចំណូលនេះរួមមានៈ ចំណូលសារពើពន្ធក្នុងប្រទេស និងចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស។ ចំណូលសារពើពន្ធក្នុងស្រុក កត់ត្រាចំណូលទទួលបានពីពន្ធដារ និងពន្ធគយក្នុងប្រទេស។[៥]

### ឃ. ច្បាប់បទបញ្ញត្តិ និងនីតិវិធីសម្រាប់ការគ្រប់គ្រងថវិកា

សៀវភៅណែនាំស្តីពីហិរញ្ញវត្ថុ និងរដ្ឋបាល(សៀវភៅណែនាំ) គឺអាស្រ័យលើនីតិវិធីរួមបច្ចុប្បន្នកម្មនៃរាជរដ្ឋាភិបាលកម្ពុជា និងរួមបញ្ចូលនូវតម្រូវការជាក់លាក់របស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សៀវភៅណែនាំនេះមានគោលបំណងផ្តល់នូវគោលនយោបាយ និងនីតិវិធីនៃការគ្រប់គ្រង និងបុគ្គលិករបស់កម្មវិធីដើម្បីគ្រប់គ្រងប្រាក់ចំណូលនិងចំណាយរបស់មូលនិធិនិងការគ្រប់គ្រងទ្រព្យតាមរបៀបត្រឹមត្រូវនិងល្អបំផុត។ សៀវភៅណែនាំនេះ ជួយផ្តល់នូវរបាយការណ៍ហិរញ្ញវត្ថុទាន់ពេលវេលា និងអាចជឿទុកចិត្តបានពីប្រព័ន្ធគណនេយ្យ។ សៀវភៅណែនាំនេះត្រូវបានអនុវត្តចំពោះភ្នាក់ងារដែលបានអនុវត្តកម្មវិធីទាំងអស់ដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដូចជាអគ្គនាយកដ្ឋាន ឬនាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ននានា។ នៅទីបញ្ចប់សៀវភៅណែនាំ បញ្ចូលការត្រួតពិនិត្យផ្ទៃក្នុងហិរញ្ញវត្ថុ និងរដ្ឋបាលនិងផ្តល់នូវមគ្គុទ្ទេសក៍ជាជំហានៗស្តីពីនីតិវិធីសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ និងសកម្មភាពរដ្ឋបាលដើម្បីការពារកុំអោយមានកំហុសឆ្គង ឬការក្លែងបន្លំនៅពេលមានការកើតឡើងដើម្បីធានាឱ្យមានការរកឃើញទាន់ពេលវេលា។ សៀវភៅណែនាំនេះ ក៏បានផ្តល់ការណែនាំលើគ្រប់ផ្នែកទាំងអស់នៃការគ្រប់គ្រងហិរញ្ញវត្ថុពីគោលនយោបាយ និងបទដ្ឋានហិរញ្ញវត្ថុថវិកាប្រព័ន្ធ គណនេយ្យភាពហិរញ្ញវត្ថុ និងនីតិវិធីហិរញ្ញវត្ថុ របាយការណ៍ហិរញ្ញវត្ថុ និងសវនកម្ម។ ប្រព័ន្ធគណនេយ្យបន្ថែមទៅនឹងដំណើរការដែលបានកំណត់នៅក្នុងសៀវ

[៥] ច្បាប់កែតម្រូវស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០

គោលការណ៍ណែនាំត្រូវបានប្រើប្រាស់ដើម្បីធានាដល់របាយការណ៍ហិរញ្ញវត្ថុទាន់ពេលវេលា និងត្រឹមត្រូវសម្រាប់ការគ្រប់គ្រងកម្មវិធី និងសម្រួលដល់ការគ្រប់គ្រង និងវិភាគហិរញ្ញវត្ថុ។ គោលនយោបាយ និងនីតិវិធីដែលគ្រប់គ្រងការអនុវត្តប្រព័ន្ធដោយឡែកពីសៀវភៅគណនេយ្យ គណនេយ្យកុំព្យូទ័រត្រូវបានគ្របដណ្តប់សៀវភៅណែនាំនេះគួរតែត្រូវបានធ្វើបច្ចុប្បន្នភាពជាទៀងទាត់ដោយផ្អែកលើបទពិសោធដែលទទួលបានក្នុងអំឡុងពេលនៃការអនុវត្តកម្មវិធីដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តន៍គួរតែមានការផ្លាស់ប្តូរនៅក្នុងកាលៈទេសៈនៃកម្មវិធី។ អគ្គនាយកដ្ឋានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទទួលខុសត្រូវចំពោះការធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំ និងរក្សាការគ្រប់គ្រង និងបុគ្គលិករបស់កម្មវិធីទាំងអស់ដែលបានជូនដំណឹងពីការផ្លាស់ប្តូរដែលបានធ្វើឡើង។ សៀវភៅណែនាំណាក៏ដោយត្រូវកំណត់ឯកសារត្រូវបានអនុវត្តពីមួយពេលទៅមួយពេលតែងតែមានការងារមិនបន្ទាន់ប្រចាំថ្ងៃដែលកើតឡើងដែលអាចនៅក្រៅជំនាញបច្ចេកទេសជំនួយការជំនាញពីខាងក្នុង។ មានកម្រិតជំនាញមួយចំនួនលើផ្នែកបុគ្គលិកគណនេយ្យ និងកម្រិតការគ្រប់គ្រងត្រួតពិនិត្យមួយចំនួនដើម្បីមើលថានីតិវិធីដែលបានកត់ត្រា និងបទពិសោធន៍របស់បុគ្គលិកនៅក្នុងកម្មវិធី។ [៦]

## ១.៣.ប្រសិទ្ធភាពថវិកា

គោលការណ៍សំខាន់ៗ នៃការរៀបចំថវិកាឆ្នាំ២០១៧ដែលប្រកបដោយប្រសិទ្ធភាពរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖

១. ការរិះរក និងឆ្លុះរកប្រភពចំណូលៈ ដើម្បីបង្កើនចំណូលថវិកាឱ្យអស់លទ្ធភាព ហើយផ្អែកលើមូលដ្ឋាននេះ គិតគូររៀបចំចំណាយឱ្យកាន់តែចំទិសដៅគោលនយោបាយ និងសន្សំសំចៃខ្ពស់ ។

២. ការកំណត់លំដាប់អាទិភាពៈ តាមរយៈការបន្តនូវភាពម៉ឺងម៉ាត់ និងការសម្រួចលើការលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជដោយផ្តោតការយកចិត្តទុកដាក់ទៅលើវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល ព្រមទាំងទៅលើកម្មវិធី/សកម្មភាពចាំបាច់ជាអាទិភាពរបស់ក្រសួង-ស្ថាប័ន។ ក្នុងន័យនេះកំណើនថវិកាត្រូវបានផ្តល់អាទិភាពជាសំខាន់ទៅលើកម្មវិធី/អនុកម្មវិធី/សកម្មភាពណាដែលអាចរំពឹងថានឹងសម្រេចបានលទ្ធផលជាក់លាក់ជាពិសេសសកម្មភាពណាដែលអាចសម្រេចបានលទ្ធផលច្រើនដោយចាយថវិកាតិច។ លើសពីនេះក្នុងករណីដែលលទ្ធភាពថវិកានៅតែមិនអាចឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពថ្មីរបស់ក្រសួង-ស្ថាប័ន មុខចំណាយជាប្រចាំមួយចំនួនក៏ត្រូវបានយកមកពិនិត្យធ្វើអាទិភាពឡើងវិញដែរ ។

៣.ការយកចិត្តទុកដាក់លើមនុស្សៈទន្ទឹមនឹងបន្តបង្កើនប្រាក់បៀវត្សអប្បបរមា ជូនមន្ត្រីរាជការគ្រប់ប្រភេទឆ្ពោះទៅច្រើនជាង១លានរៀល នៅឆ្នាំ២០១៨ ថវិកាឆ្នាំ២០១៧បានដាក់ចេញថែមទៀត នូវវិធានការពន្ធដារពាក់ព័ន្ធនឹងការសម្រួលកម្រិតជាប់ពន្ធនៃប្រាក់បៀវត្សដើម្បីផ្តល់ការលើកទឹកចិត្ត និងរួមចំណែកលើកកម្ពស់ជីវភាពដល់មន្ត្រីរាជការ ពិសេសគ្រូបង្រៀន និងគ្រូពេទ្យ ព្រមទាំងកម្មករនិយោជិតដែលមានបៀវត្សទាប។ លើសពីនេះថវិកាឆ្នាំ២០១៧ ក៏បានផ្តល់អាទិភាពដល់ការកសាង និងពង្រឹងធនធានមនុស្ស និងផ្តល់ការយក

[៦] សៀវភៅណែនាំអំពីការការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០២១

ចិត្តទុកដាក់ដល់ការឧបត្ថម្ភគាំទ្រចំពោះមនុស្សដែលត្រូវទទួលខុសត្រូវក្នុងការអនុវត្តការងារផ្ទាល់ ក៏ដូចជាការពង្រឹងគុណភាពសេវាសាធារណៈ ដែលផ្តល់ប្រយោជន៍ផ្ទាល់ដល់ប្រជាជនទូទៅ ។

៤. ការកំណត់តម្លៃជាក់ស្តែងនៃកម្មវិធី/សកម្មភាពៈ ដោយគិតគូរឱ្យកាន់តែហ្មត់ចត់លើភាពសមស្របនៃថ្លៃបរិមាណ និងគុណភាពក្នុងការអនុវត្ត កម្មវិធី/សកម្មភាព តាំងពីក្នុងដំណាក់កាលនៃការរៀបចំថវិកាចៀសវាងការលើកគម្រោងចំណាយមានលក្ខណៈចោលៗ និងក្នុងលក្ខណៈប្រចុចប្រញ៉ច ដែលធ្វើឱ្យការវិភាជថវិកាមិនសូវមានប្រសិទ្ធភាព ហើយខ្វះខ្ទាយថវិកានៅពេលអនុវត្ត ។

៥. ការផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្តៈ ពិសេសនៅក្នុងវិស័យអាទិភាព ពោលគឺ វិស័យអប់រំ និងសុខាភិបាល, ដោយបង្កើនការផ្ទេរថវិកាឱ្យទៅដល់អង្គភាពអនុវត្តការងារផ្ទាល់ ដែលនៅក្រោមឱវាទក្រសួង-ស្ថាប័ននៅរដ្ឋបាលកណ្តាលឬនៅតាមមូលដ្ឋានដូចជាសាលារៀនមន្ទីរពេទ្យ និងមណ្ឌលសុខភាពជាដើម។ល។ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពចំណាយ ជាពិសេសធានាបាននូវភាពទាន់ពេលវេលា និងការទទួលខុសត្រូវច្បាស់លាស់នៅក្នុងការគ្រប់គ្រង និងចាត់ចែងអនុវត្តថវិកា ។

៦. ការផ្សារភ្ជាប់រវាងការប្រមូលចំណូល និងការវិភាជថវិកាៈ តាមរយៈវិធានការផ្សារភ្ជាប់ការវិភាជថវិកាទៅនឹងលទ្ធផលនៃការអនុវត្តចំណូល ជាពិសេសផ្តល់អាទិភាពលើចំណាយមិនមែនបុគ្គលិកដល់ក្រសួងស្ថាប័នដែលកៀរគរចំណូលបានដោយការខិតខំអនុវត្តសកម្មភាពប្រមូលចំណូល ហើយបានបង់ចំណូលមួយភាគធំចូលថវិការដ្ឋ ទន្ទឹមនឹងការរឹតត្បិតលើការស្នើសុំបង្កើនថវិកា ចំពោះក្រសួង-ស្ថាប័នដែលការប្រមូលចំណូលមិនអាចសម្រេចបានលទ្ធផលសមស្របតាមសក្តានុពលជាក់ស្តែង ឬដែលមានទំហំចំណែកប្រាក់រង្វាន់ធំ ។

៧. ការរក្សាតុល្យភាពថវិកាៈ ទោះបីជាស្ថិតក្រោមសម្ពាធនៃតម្រូវការចំណាយ ដែលចេះតែកើនឡើងជាលំដាប់ ជាពិសេសសម្ពាធនៃចំណាយបន្ទុកបុគ្គលិក ចំណាយចរន្តមិនមែនបន្ទុកបុគ្គលិកដែលកើតឡើងថ្មីៗព្រមទាំងចំណាយវិនិយោគដើម្បីជំរុញការអភិវឌ្ឍក៏ដូចជាដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនហើយនៅក្នុងពេលដំណាលគ្នានេះ ការប្រមូលចំណូលក៏នៅបន្តជួបបញ្ហាប្រឈម និងហានិភ័យមួយចំនួនធំក៏ដោយ ការរៀបចំថវិកាឆ្នាំ២០១៧ត្រូវបានធ្វើលើមូលដ្ឋាននៃការធានាឱ្យបាននូវតុល្យភាព ហើយទន្ទឹមនឹងនេះក៏មានការត្រៀមបម្រុងសម្រាប់សេចក្តីត្រូវការមិនបានគ្រោងទុក និងសម្រាប់ការធ្វើអន្តរាគមន៍ចាំបាច់ជាយថាហេតុរបស់រាជរដ្ឋាភិបាលក្នុងវិស័យសេដ្ឋកិច្ច និងសង្គមផងដែរ ។

៨. ការគ្រប់គ្រងបំណុលសាធារណៈ ប្រកាន់ខ្ជាប់នូវគោលការណ៍គន្លឹះចំនួន០៤ របស់សម្តេចតេជោនាយករដ្ឋមន្ត្រី គឺៈ ត្រូវខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រទ្រង់បាន ត្រូវខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់ ត្រូវខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់[៧]ចីរភាពនៃកំណើន និងវិស័យបង្កើនផលិតភាព និងប្រសិទ្ធភាពសេដ្ឋកិច្ចត្រូវប្រើប្រាស់ឥណទានទាំងនោះប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់បំផុត ។

[៧] ផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០១៧-២០១៩

## ១.៣.១. នីតិវិធីគ្រប់គ្រងថវិកា

នីតិវិធីក្នុងការគ្រប់គ្រងថវិកាដែលមានប្រាក់រជ្ជទេយ្យ និងបុរេទាន។

ប្រាក់រជ្ជទេយ្យ ត្រូវបានប្រើប្រាស់សម្រាប់ចំណាយតូចតាច (ចំណាយរដ្ឋបាល) ដែលកើតឡើងសម្រាប់គម្រោង។ គោលបំណងទូទៅដែលបានអនុម័តរួចសម្រាប់ការប្រើប្រាស់ប្រាក់រជ្ជទេយ្យ ដែលអាចទទួលបានការគាំទ្រហិរញ្ញវត្ថុរួមមាន៖ ការផ្គត់ផ្គង់សម្ភារៈការិយាល័យ និងសម្ភារៈតូចតាច ថតចម្លងឯកសារ ទឹកថ្នាំសម្រាប់ម៉ាស៊ីនព្រីន ការជួសជុស និងការថែទាំឧបករណ៍ក្នុងការិយាល័យតូចតាចចំណាយតិចតួចលើការថែទាំរថយន្ត ការចំណាយលើការទំនាក់ទំនងលើប្រព័ន្ធអីនធើណេត សារអេឡិចត្រូនិច ទូរសារ អាហារសម្រន់ក្នុងការិយាល័យមាន តែ កាហ្វេ និងទឹក បុរេប្រទានសម្រាប់បុគ្គលិកធ្វើបេសកម្មធ្វើដំណើរបំពេញការងារ ការលាងរថយន្ត ថ្លៃឆ្លងកាត់ ឆ្លងសាឡាង ចំណាយលើអាហារ ការថតចម្លងឯកសារ បោះពុម្ពចំណាយក្នុងការធ្វើដំណើរ អាហារសម្រន់ក្នុងវគ្គបណ្តុះបណ្តាលសិក្ខាសាលា អាហារ (ថ្ងៃត្រង់ និងពេលល្ងាច)

សម្រាប់ក្រុមការងារ និងចំណាយជាសាច់ប្រាក់តូចតាច។ ប្រាក់រជ្ជទេយ្យបុរេប្រទានគួររក្សាទុកដោយជំនួយការគណនេយ្យ/មន្រ្តីទទួលបន្ទុក។ វាជាការដកប្រាក់មួយដងពីគណនីធនគារគម្រោង។ គណនីសាច់ប្រាក់អាចត្រូវបង្កើតឡើងសម្រាប់អង្គភាពអនុវត្តគម្រោងណាមួយដើម្បីជួយសម្រួលដល់ការអនុវត្តសកម្មភាពកែទម្រង់ដោយមានការយល់ព្រមជាមុនពីអគ្គលេខាធិការដ្ឋាន។ វិសាលភាពសម្រាប់ប្រាក់រជ្ជទេយ្យ បុរេប្រទានបន្ថែមជាក់លាក់អាចត្រូវបានកំណត់ជាក់លាក់ជាលាយលក្ខណ៍អក្សរដោយមិនបាច់កែប្រែឡើយ។ ការចំណាយប្រាក់រជ្ជទេយ្យអាចបំពេញបន្ថែមញឹកញ៉ាប់តាមតម្រូវការដោយមិនមានការកំណត់ចំនួនដងសម្រាប់ការបំពេញបន្ថែមសាច់ប្រាក់ណាមួយឡើយឲ្យតែស្ថិតក្នុងកម្រិតថវិកាដែលមាន។ ការចំណាយដាក់ស្តែងក្រោមប្រាក់រជ្ជទេយ្យ គួរត្រូវបានគាំទ្រដោយបង្កាន់ដៃបង់ប្រាក់/វិក័យបត្រដែលមានឯកសារគាំទ្រគ្រប់គ្រាន់។សៀវភៅប្រាក់រជ្ជទេយ្យត្រូវបានរៀបចំឡើងដើម្បីកត់ត្រារាល់ប្រតិបត្តិការទាំងអស់ ដែលចុះក្នុងសម្ពីប័ត្រប្រាក់រជ្ជទេយ្យ និងសម្ពីបត្រចំណាយដែលទាក់ទងនិងប្រតិបត្តិការប្រាក់រជ្ជទេយ្យ។ វាត្រូវបានរក្សាទុកដោយជំនួយការគណនេយ្យ/បេឡាករ ដែលដើរតួនាទីជាអ្នកបន្ទាប់គ្រប់គ្រង់សាច់ប្រាក់។

បុរេប្រទាន ជាសាច់ប្រាក់ត្រូវបានផ្តល់សម្រាប់កម្មវិធីក្នុងការអនុវត្តសកម្មភាពដែលបានអនុម័តរួចក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ តែវាមិនត្រូវបានអនុវត្តសម្រាប់ការទូរទាត់វិក័យបត្រ ឬកិច្ចសន្យានោះទេ។ ជាទូទៅបុរេប្រទានត្រូវបានប្រើប្រាស់សម្រាប់ ការបណ្តុះបណ្តាល/សិក្ខាសាលា និងបេសកម្មទាំងក្នុង និងក្រៅប្រទេស។ បុរេប្រទានជាសាច់ប្រាក់ ត្រូវគ្រប់គ្រងដោយមន្រ្តីត្រួតពិនិត្យហិរញ្ញវត្ថុដោយមាន ជំនួយពីគណនេយ្យករ/ជំនួយការគណនេយ្យដើម្បីធានាថាការជម្រះបញ្ជីចំនាយចំនាយដែលកើតមាន ត្រូវបានធ្វើឡើងក្នុងរយៈពេល១៥ថ្ងៃធ្វើការបន្ទាប់ពីសកម្មភាពដែលទទួលបានក្នុងបុរេប្រទានបានបញ្ចប់។ ការបើកផ្តល់បុរេប្រទាននីតិវិធីខាងក្រោមប្រើសម្រាប់បុរេប្រទានដែលត្រូវបានអនុម័តរួចហើយដោយថ្នាក់ដឹកនាំកម្មវិធី។ គោលការណ៍និងនីតិវិធីលំអិត សម្រាប់ការស្នើសុំអនុម័ត និងបុរេប្រទាន សម្រាប់ការបណ្តុះបណ្តាល ទស្សនកិច្ចសិក្សា

ដែលបេសកម្មត្រូវបានចែងនៅផ្នែកទី១៦ នៃសៀវភៅគោលការណ៍ការណែនាំបន្ថែម ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ។ តាមគោលការណ៍ណែនាំទូទៅ បុរេប្រទានត្រូវបានផ្តល់ជូន១០% នៃថវិកាប៉ាន់ប្រមាណសម្រាប់សោហ៊ុយបេសកម្ម ឬសម្រាប់ថវិកាប៉ាន់ប្រមាណក្នុងការអនុវត្តសកម្មភាពទាំងមូល លើកលែងតែមុខសញ្ញាដែលចំណាយទាក់ទងកិច្ចសន្យាផ្គត់ផ្គង់ដែលតម្រូវឲ្យធ្វើការទូទាត់ត្រង់ទៅអ្នកផ្គត់ផ្គង់ សម្រាប់ចំណាយដែលមានទឹកប្រាក់ច្រើន។ បុគ្គលស្នើសុំប្រាក់បុរេប្រទានត្រូវបំពេញបែបបទស្នើសុំ ឬក៏រៀបចំលិខិតស្នើសុំមកកាន់អគ្គលេខាធិការគណនេយ្យដើម្បីចាត់ចែងបន្តទៅ អគ្គលេខាធិការរងទទួលបន្ទុក និងមន្ត្រីពាក់ព័ន្ធ។ បុរេប្រទាន អាចដកចេញពីគណនីគម្រោង ឬប្រាក់រជ្ជទេយ្យ ទៅតាមទំហំថវិកាស្នើសុំដូចមានចែង។[៩]

### ១.៣.២. ការប្រើប្រាស់ថវិកាក្នុងការអភិវឌ្ឍន៍

ថវិការបស់រដ្ឋបាល ក្រុង ខណ្ឌ និងឃុំសង្កាត់ត្រូវបានរាប់បញ្ចូលក្រោមថវិការបស់ក្រុងដែលខ្លួនស្ថិតនៅក្រោម។ថវិកាទាំងនេះគឺផ្អែកលើការបែងចែកនិងផ្ទេរថវិកាឃុំ សង្កាត់ និងចំណូលដែលប្រមូលដោយរដ្ឋបាលក្រុងខណ្ឌ និងឃុំ សង្កាត់ ។ ថវិកាទាំងនេះត្រូវបានផ្អែកលើគោលបំណង នៃគោលនយោបាយកម្មវិធី អនុកម្មវិធី និងអាទិភាព និងចង្កោមសកម្មភាពដែលពណ៌នាអំពីគោលបំណង និងសូចនាករគោលដៅពេលវេលា និងថវិកាដែលត្រូវការ ។

ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រតិទិនថវិការបស់រដ្ឋបាល ក្រុង ខណ្ឌ និងឃុំសង្កាត់ត្រូវបានរាប់បញ្ចូលក្រោមថវិការបស់ក្រុងដែលខ្លួនស្ថិតនៅក្រោម។ ថវិកាទាំងនេះគឺផ្អែកលើការបែងចែក និងផ្ទេរថវិកា ឃុំ សង្កាត់ និងចំណូលដែលប្រមូល ដោយរដ្ឋបាល ក្រុង ខណ្ឌ និងឃុំសង្កាត់។ ថវិកាទាំងនេះត្រូវបានផ្អែកលើគោលបំណង នៃគោលនយោបាយ កម្មវិធី អនុកម្មវិធី និងអាទិភាព និងចង្កោមសកម្មភាព ដែលពណ៌នាអំពីគោលបំណង និងសូចនាករគោលដៅ ពេលវេលា និងថវិកាដែលត្រូវការ ។

យោងតាមមាត្រាសម្រាប់សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំត្រូវបែងចែកជា ៣ ដំណាក់កាល៖

1. ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ( ចាប់ពីខែមីនា ដល់ ឧសភា) ៖ នៅពេលទទួលបានសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាដែលចេញដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពទាំងអស់ជូនដំណឹងដល់ក្រុមប្រឹក្សានីមួយៗ អំពីកម្មវិធី និងការព្យាករណ៍ថវិកា ក្នុងវិស័យរបស់ពួកគេដែលចាំបាច់ត្រូវអនុវត្ត ។
2. ការរៀបចំកញ្ចប់ថវិកា( ចាប់ពីខែមិថុនាដល់ខែកញ្ញា )៖នៅសប្តាហ៍ដំបូងនៃខែមិថុនារដ្ឋមន្ត្រីក្រសួង

[៩] គោលការណ៍ណែនាំបន្ថែមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២១

3. សេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំជាសារាចរណែនាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិស្ដីពីបច្ចេកទេសសម្រាប់ការរៀបចំផែនការថវិកា។សារាចរនេះបញ្ជាក់ពីទម្រង់នីតិវិធីនិងឯកសារគាំទ្រនានាដែលត្រូវប្រើដើម្បីរៀបចំផែនការចំណូល និងចំណាយលម្អិត ។
4. ការអនុម័តថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ (ពីខែតុលាដល់ខែធ្នូ)៖ នៅក្នុងសប្ដាហ៍ដំបូងនៃខែតុលាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដាក់ផែនការថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។[៩]

# ជំពូក២

# ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

## ២.១. រចនាសម្ព័ន្ធថវិការដ្ឋបាលថ្នាក់ជាតិ

នៅក្នុងប្រទេសកម្ពុជារដ្ឋបាលសាធារណៈចែកចេញជាពីរកម្រិតរួមមាន រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ រដ្ឋបាលទាំង២កម្រិតមានគោលបំណងតែមួយ គឺសម្រេចឲ្យបាននូវគោលនយោបាយជាអាទិភាពមួយដែលសំខាន់។

ស្ថាប័នជាតិមួយចំនួនមានចែងក្នុងរដ្ឋធម្មនុញ្ញហើយមួយចំនួនទៀតមានប្បញ្ញត្តិក្នុងច្បាប់។ខណៈដែលស្ថាប័នជាតិត្រូវបង្កើតឡើងដោយច្បាប់ ឬព្រះរាជក្រឹត្យ ការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នទាំងនេះត្រូវកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល (ដើម្បីស្វែងយល់អំពីប្រភេទឋានានុក្រម និងនីតិវិធីច្បាប់នៃអត្ថបទច្បាប់ពាក់ព័ន្ធសូមចូលទៅកាន់ច្បាប់ និងប្រព័ន្ធតុលាការ ។

កំណែទម្រង់គួរឲ្យកត់សម្គាល់ដែលកើតឡើងជាមួយនឹងស្ថាប័នជាតិភាគច្រើនកើតឡើងភ្លាមៗនៅក្រោយពីការបោះឆ្នោតជាតិឆ្នាំ២០១៣។ ស្ថាប័នជាតិទាំងនោះលែងដាក់ឲ្យស្ថិតនៅក្រោមទីស្ដីការគណៈរដ្ឋមន្ត្រីហើយប៉ុន្តែនៅក្រោមក្រសួងទទួលបន្ទុកនៃរាជរដ្ឋាភិបាល។ ចំនួន៤កំណែទម្រង់នេះ មានគោលដៅរៀបចំ និងដាក់បញ្ចូលស្ថាប័នជាតិទទួលបន្ទុកតាមវិស័យទាំងនោះទៅក្នុងរចនាសម្ព័ន្ធនៃក្រសួងជាប់ពាក់ព័ន្ធ ។

បញ្ជីឈ្មោះក្រសួង និងស្ថាប័នជាតិនៃរាជរដ្ឋាភិបាលមានដូចខាងក្រោមនេះ។ តំណភ្ជាប់នីមួយៗនឹងផ្ដល់ជូនព័ត៌មានលម្អិតបន្ថែមអំពីយុត្តាធិការ និងវិស័យទទួលខុសត្រូវរបស់ក្រសួង ឬស្ថាប័នជាតិនីមួយៗ។ បណ្ដុំនៃព័ត៌មាន និងទិន្នន័យអាចរកបាននៅតាមគេហទំព័ររបស់ក្រសួង និងស្ថាប័ននីមួយៗ។

ក្រសួងស្ថាប័នមាន៖ ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ក្រសួងមុខងារសាធារណៈ ក្រសួងពាណិជ្ជកម្ម ក្រសួងធម្មការនិងសាសនា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអប់រំយុវជននិងកីឡា ក្រសួងបរិស្ថាន ក្រសួងការបរទេស និងសហប្រតិបត្តិការ ក្រសួងសុខាភិបាល ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងរ៉ែ និងថាមពល ក្រសួងការពារជាតិ ក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចក្រសួងផែនការ ក្រសួងប្រៃសណីយ៍

[៩] ច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ខេត្តក្រុង មាត្រា១ និងមាត្រា២

និងទូរគមនាគមន៍ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងទេសចរណ៍ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកិច្ចការនារី រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

ស្ថាប័នជាតិសំខាន់ៗៈធនាគារជាតិនៃកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្រុមប្រឹក្សាធម្មនុញ្ញ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត វិទ្យាស្ថានជាតិស្ថិតិ អាជ្ញាធរទន្លេសាប អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី អាជ្ញាធរជាតិអប្សរា អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយមីន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

គោលនយោបាយថ្នាក់ជាតិតាមវិស័យ ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គោលនយោបាយតាមវិស័យក្របខណ្ឌចំណូល និងចំណាយផែនការយុទ្ធសាស្ត្រថវិកា និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងប្រចាំឆ្នាំ។

សំគាល់:

១.ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈសម្រាប់គ្រប់គ្រងប្រចាំឆ្នាំអនុម័តដោយនីតិបញ្ញត្តិ។

២.គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច/គោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយតាមវិស័យគឺត្រូវធ្វើដោយស្ថាប័នថ្នាក់ជាតិ និងសម្រាប់ជាតិទាំងមូល។

៣. ផ្អែកលើ ១និង២ ក្រសួងស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំក្របខណ្ឌចំណូល និងចំណាយរយៈពេលមធ្យមនិងផែនការយុទ្ធសាស្ត្រថវិកាដើម្បីសុំការអនុម័តនិងសម្រាប់ជាមូលដ្ឋាននៃការរៀបចំថវិកាប្រចាំឆ្នាំរបស់ខ្លួនដើម្បីសុំការអនុម័តតាមលំដាប់លំដោយនៃឋានានុក្រម ដើម្បីដាក់បញ្ចូលក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំរបស់ជាតិទាំងមូល និងការសុំការអនុម័តពីអង្គការនីតិបញ្ញត្តិរៀងរាល់ឆ្នាំ។

<u>គោលនយោបាយថ្នាក់ជាតិ/អាទិភាពនៃផែនការយុទ្ធសាស្ត្រ/គោលនយោបាយតាមវិស័យ</u>

ក្រសួងស្ថាប័នវិសហមជ្ឍការប្រើផែនការយុទ្ធសាស្ត្រថ្នាក់ជាតិថវិកាកម្មវិធី(លទ្ធផលចុងក្រោយ) ចំណែកឯមន្ទីរក្រុង-ខេត្ត ប្រើប្រាស់យុទ្ធសាស្ត្រចង្កោមនៃអនុកម្មវិធី (លទ្ធផលក្នុងឆ្នាំ) ការិយាល័យស្រុកប្រើប្រាស់គោលនយោបាយចង្កោមសកម្មភាព(លទ្ធផលក្នុងឆ្នាំ)។

ក្រុមប្រឹក្សារាជធានីខេត្តវិមជ្ឈការផែនការយុទ្ធសាស្ត្រថវិកា រាជធានីខេត្ត/ចង្កោមថវិកា នៃកម្មវិធី (លទ្ធផលក្នុងឆ្នាំ/លទ្ធផលចុងក្រោយ)បន្ទាប់មករដ្ឋបាលរាជធានីខេត្ត អនុវត្តចង្កោមអនុកម្មវិធីលទ្ធផលក្នុងឆ្នាំ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ប្រើគោលនយោបាយតាមវិស័យចង្កោមសកម្មភាព(លទ្ធផលក្នុងឆ្នាំ) រួមទាំងរដ្ឋបាលឃុំសង្កាត់ ប្រើសកម្មភាព(លទ្ធផលក្នុងឆ្នាំ)។[១០]

## ២.២.គោលនយោបាយហិរញ្ញវត្ថុសាធារណៈ

[១០] ទស្សនទានស្តីពីទិសដៅយុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ឆ្នាំ២០១៣-២០២០

ការរៀបចំគម្រោងថវិកា ការចរចាថវិកានិងការអនុម័តថវិកាក្នុងពេលបច្ចុប្បន្ន ទោះបីជាដំណើរការរៀបចំគម្រោងថវិកាក្រសួងស្ថាប័ន និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិធ្វើឡើងតាមដំណើរការពីរផ្សេងគ្នាក្តីក៏ការរៀបចំថវិកាទាំងពីរនេះជួបប្រសព្វគ្នានៅកម្រិតរាជធានីខេត្ត។ ថវិកាមន្ទីរជំនាញរាជធានី ខេត្តត្រូវបានរៀបចំដោយក្រសួងស្ថាប័នដោយផ្អែកលើផែនការនីយកម្មពីលើចុះក្រោមទៅនីតិប្បញ្ញត្តិជាផ្នែកមួយនៃថវិកាជាតិ។ ថវិការដ្ឋបាលថ្នាក់រាជធានីខេត្តត្រូវបានរៀបចំ និងដាក់ឱ្យក្រុមប្រឹក្សាអ្នកតាមអាទិភាពជាតិហើយត្រូវបានចរចា និងយល់ព្រមដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួចអនុម័តដោយស្ថាប័នខេត្តពិនិត្យ និងអនុម័ត ហើយត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីចរចា និងយល់ព្រម និងបូកសរុបដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។ ដោយឡែក ថវិកាសរុបសម្រាប់ ក្រុង ស្រុក និងថវិកាសម្រាប់ឃុំសង្កាត់ត្រូវបានវិភាជក្នុងសមាមាត្រជាក់លាក់នៃចំណូលចរន្តថ្នាក់ជាតិឆ្នាំកំពុងអនុវត្ត។ ទំហំនៃការវិភាជនេះត្រូវកំណត់ដោយផ្អែកតាមរូបមន្តជាក់លាក់មួយដែលជាអនុគមន៍នៃចំណែកស្មើៗគ្នា ទំហំប្រជាជនសន្ទស្សន៍នៃភាពក្រីក្រចំនួនក្រុមប្រឹក្សា និងចំនួនឃុំ សង្កាត់ (សម្រាប់ ក្រុង ស្រុក) ឬចំនួនភូមិ (សម្រាប់ឃុំ សង្កាត់)។ រដ្ឋបាលរាជធានីខេត្តផ្តល់នូវការគាំទ្របច្ចេកទេសដល់ការរៀបចំថវិកាក្រុងស្រុក។ បន្ទាប់ពីក្រុមប្រឹក្សាធ្វើការត្រួតពិនិត្យ និងអនុម័តថវិកាក្រុង ស្រុករួច មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើការបូកសរុបថវិកានេះ នៅតាមខេត្តនីមួយៗរួចបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ រដ្ឋបាលឃុំ-សង្កាត់នីមួយៗរៀបចំថវិកាដោយខ្លួនឯងរួចដាក់ឱ្យក្រុមប្រឹក្សាខ្លួនពិនិត្យ និងអនុម័ត បន្ទាប់មកបញ្ជូនទៅរាជធានី-ខេត្តដើម្បីត្រួតពិនិត្យ និងផ្តល់អនុលោមភាពថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុម័តជាកញ្ចប់ដោយស្ថាប័ននីតិប្បញ្ញត្តិជាផ្នែកមួយនៃថវិកាជាតិ។ មន្ទីរជំនាញរាជធានី-ខេត្តមិនមានពាក់ព័ន្ធនៅក្នុងដំណើរការរៀបចំគម្រោងថវិកានេះទេ។ ទោះបីជាមានដំណើរការរៀបចំគម្រោងថវិកា ការចរចាថវិកា និងការអនុម័តថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិច្បាស់លាស់ បែបនេះក្តីក៏ថវិការដ្ឋបាលថ្នាក់ក្រោមជាតិនៅមានបញ្ហាផ្នែកគុណភាព ភាពគ្រប់ជ្រុងជ្រោយ និងភាពមិនច្បាស់លាស់នៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។

គោលបំណងនៅឆ្នាំ២០២៥ គឺធ្វើឱ្យថវិការដ្ឋបាលថ្នាក់ក្រោមជាតិមានភាពគ្រប់ជ្រុងជ្រោយដោយពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។ ថវិកាចរន្ត និងថវិកាមូលធននឹងត្រូវធ្វើសមាហរណកម្ម។ ការចរចាថវិការដ្ឋបាលថ្នាក់រាជធានី-ខេត្តនឹងតម្រង់ទិសឆ្ពោះទៅរកការផ្តោតលើលទ្ធផលក្នុងឆ្នាំនៃកម្មវិធី។ ដោយសារប្លង់គណនីតម្រូវឱ្យមានការឯកភាពគ្នាហើយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនឹងត្រូវដាក់ពង្រាយទៅដល់រដ្ឋបាលរាជធានី-ខេត្ត ដូចនេះ ចំណាត់ថ្នាក់ថវិកានឹងត្រូវប្រើដូចគ្នានឹងថ្នាក់ជាតិដែរ។ ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនឹងមានតែមួយ ដែលរួមមានថវិកាថ្នាក់ជាតិ និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។ ថវិការដ្ឋបាលរាជធានី-ខេត្តនឹងឆ្លុះបញ្ចាំងជាសរុបតាមខេត្តនីមួយៗដោយចែកជាថវិកាចរន្ត និងថវិកាមូលធនជាឧបសម្ព័ន្ធនៃច្បាប់។ ដោយឡែកថវិការបស់រដ្ឋបាលក្រុង ស្រុក និងឃុំសង្កាត់នឹងត្រូវឆ្លុះបញ្ចាំងជាទំហំសរុបដែលជាលទ្ធផលនៃការវិភាជលទ្ធិតតាមរដ្ឋបាលនីមួយៗ ដោយផ្អែក

លើរូបមន្តបែងចែកជាក់លាក់ និងផ្អែកលើសមិទ្ធកម្ម។ នៅពេលខាងមុខ នៅពេលប្រព័ន្ធគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែត្រូវបានកែលម្អគោលការណ៍នយោបាយថវិកា។

ការរៀបចំ និងអនុម័តថវិកានឹងត្រូវពិនិត្យឡើងវិញស្របតាមឧត្តមានុវត្តជាអន្តរជាតិ។ ជារួមការកែទម្រង់ការរៀបចំថវិកា ការចរចាថវិកាការយល់ព្រមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុព្រមទាំងការដាក់ជូនគណៈរដ្ឋមន្ត្រី និងស្ថាប័ននីតិប្បញ្ញត្តិពិនិត្យ និងអនុម័តគឺត្រូវធ្វើឱ្យស៊ីចង្វាក់គ្នានៅក្រោមគោលការណ៍នៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ជាតិ។

<u>ទំនាក់ទំនងរវាងរដ្ឋបាលទាំង២កម្រិតសម្រាប់ការអនុវត្តអាទិភាពគោលនយោបាយជាតិ</u>

រដ្ឋបាលថ្នាក់ជាតិ ក្រសួងស្ថាប័នត្រួតពិនិត្យថវិកា មន្ទីររាជធានី ខេត្ត និងការិយាល័យ ក្រុង ស្រុក។

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រួតពិនិត្យថវិកា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

### ២.២.១.ចំណាយថវិកាថ្នាក់ជាតិ

ប្រព័ន្ធថវិកាជាតិឆ្នាំ២០២០ ដែលបានកំណត់ខាងលើ គឺជាប្រព័ន្ធថវិកាផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម ដែលទាមទារឱ្យមានរចនាសម្ព័ន្ធគោលនយោបាយ (គោលបំណងគោលនយោបាយកម្មវិធីៈ អនុកម្មវិធី -ចង្កោមសកម្មភាព និងសកម្មភាព) ច្បាស់លាស់ និងរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន (កម្រិតដឹកនាំគ្រប់គ្រង និងបច្ចេកទេស)សមស្របព្រមទាំងមានការកំណត់សិទ្ធិអំណាច និងការទទួលខុសត្រូវច្បាស់លាស់នៅគ្រប់កម្រិតដូចមានបង្ហាញនៅក្នុងដ្យាក្រាម២ខាងលើទើបអាចអនុវត្តទៅប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពឲ្យបានលើសពីនេះទៅទៀតគឺព្យាក្រាម១បានបង្ហាញអំពីទំនាក់ទំនងនៃការផ្សារភ្ជាប់ថវិកាប្រចាំឆ្នាំទៅនឹងគោលនយោបាយដែលគោលនយោបាយទាំងនោះអាចមានច្រើនកម្រិត និងត្រូវបានអនុម័តដោយកម្រិតខុសៗគ្នាថែមទៀតផងដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំត្រូវអនុម័តដោយអង្គការនីតិបញ្ញត្តិ។ ដូច្នេះប្រព័ន្ធថវិកានេះគួរតែត្រូវបានប្រើប្រាស់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបាននូវប្រព័ន្ធមានឯកភាព សង្គតិភាព ភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាព ក្នុងការគ្រប់គ្រងថវិកា និងជាពិសេសត្រូវគោរពតាមគោលការណ៍គ្រឹះនៃថវិកាទាំង១១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ទន្ទឹមនឹងនេះក្នុងការកំណត់ប្រព័ន្ធថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិគួរយកចិត្តទុកដាក់លើបណ្តាចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

១- ក្នុងពេលដែលរាជរដ្ឋាភិបាលកំពុងរៀបចំប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសការធ្វើវិមជ្ឈការ និងវិសហមជ្ឈការមុខងារ សិទ្ធិអំណាច និងការទទួលខុសត្រូវជាបណ្តើរៗទៅថ្នាក់រាជធានី–ខេត្តថ្នាក់ស្រុក-ខណ្ឌនិងថ្នាក់ឃុំ-សង្កាត់គួរតែយកមូលដ្ឋាននៃដ្យាក្រាម១និង២ខាងលើ ដើម្បីធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ពិសេសទំនាក់ទំនងរវាងគោលនយោបាយថ្នាក់ក្រោមជាតិ (រាជធានី-ខេត្ត ក្រុង -ស្រុក–ខណ្ឌ និងឃុំ- សង្កាត់) ជាមួយនឹងគោលនយោបាយថ្នាក់ជាតិតាមវិស័យ (ក្រសួង– ស្ថាប័ន និងគោលនយោបាយជាតិ (កម្រិតប្រទេសទាំងមូល) ជាមួយនឹងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងរចនាសម្ព័ន្ធគោល

នយោបាយព្រមទាំងការកំណត់សិទ្ធិអំណាច និងការទទួលខុសត្រូវឱ្យបានត្រឹមត្រូវច្បាស់លាស់ ដើម្បីធានាប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។

២- ម្យ៉ាងទៀត ថ្វីត្បិតតែទិសដៅ និងយុទ្ធសាស្ត្រខាងក្រោមនេះ ផ្តោតជាសំខាន់ទៅលើការ កែលម្អ និងការផ្លាស់ប្តូរជាជំហានៗនៃប្រព័ន្ធថវិកាថ្នាក់ជាតិប៉ុន្តែមូលដ្ឋាននេះពិតជាអាចយកទៅរៀបចំជាទិសដៅ និងយុទ្ធសាស្ត្រសម្រាប់ការកែលម្អ និងផ្លាស់ប្តូរជាជំហានៗនៃប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិបាន ពិសេសការកំណត់ឱ្យបានត្រឹមត្រូវច្បាស់លាស់អំពីសិទ្ធិអំណាច និងការទទួលខុសត្រូវនៅក្នុងដំណាក់កាលទាំង ៤ នៃវដ្តថវិកា (ការរៀបចំថវិកា ការអនុម័តថវិកា ការអនុវត្តថវិកា និងការតាមដានវាយតម្លៃលទ្ធផល) នៅគ្រប់ថ្នាក់ទាំង ៣ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រប់កម្រិតនៃថ្នាក់នីមួយៗ ដើម្បីធានាភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃប្រព័ន្ធគ្រប់គ្រងថ្នាក់ក្រោមជាតិ។

៣-ដើម្បីធានាឯកត្តភាព ភាពគ្រប់ជ្រុងជ្រោយ សង្គតិភាពសុ ខដុមនីយកម្ម ពិសេសដើម្បីអាចបូកសរុបបានទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវតែរៀបចំឱ្យមានការឯកភាពទាំងប្រព័ន្ធ និងការគ្រប់គ្រងគណនេយ្យហិរញ្ញវត្ថុ និងថវិកា ដូចជាការរៀបចំប្លង់គណនេយ្យ និងចំណាត់ថ្នាក់ថវិកាឯកភាព និងការរៀបចំប្រព័ន្ធរបាយការណ៍គណនេយ្យហិរញ្ញវត្ថុឯកភាពជាដើម។ ជាពិសេស ថ្វីត្បិតតែការអនុវត្តថវិកានឹងត្រូវធ្វើវិសហមជ្ឈការនិងវិមជ្ឈការទៅតាមលំដាប់ថ្នាក់និងកម្រិតនីមួយៗ ប៉ុន្តែត្រូវរៀបចំមូលដ្ឋាននៃការរៀបចំ និងការអនុម័តថវិកាឱ្យមានការឯកភាពព្រមទាំងត្រូវដាក់ឆ្លងនិងសុំការអនុម័តតាមលំដាប់លំដោយនៃឋានានុក្រម ជាមួយនឹងការរៀបចំក្របខ័ណ្ឌ និងយន្តការតាមដានវាយតម្លៃលទ្ធផល និងសមិទ្ធកម្មឯកភាពដើម្បីធានាតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃប្រព័ន្ធថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ជាតិទាំងមូល។

ដូច្នេះផ្អែកតាមក្របខ័ណ្ឌនៃប្រព័ន្ធថវិកាថ្មីខាងលើ និងទិសដៅយុទ្ធសាស្ត្រដែលបានគូសបញ្ជាក់ខាងក្រោម បញ្ជាក់ឱ្យឃើញយ៉ាងច្បាស់អំពីភាពចាំបាច់នៃការធានាសង្គតិភាព និងភាពស៊ីសង្វាក់គ្នារវាងកំណែទម្រង់ដែលមានលក្ខណៈជាកំណែទម្រង់ប្រព័ន្ធទាំង៣គឺ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ និងកំណែទម្រង់រដ្ឋបាលសាធារណៈ ជាពិសេសទាមទារឱ្យកែទម្រង់ទាំង៣នេះ រៀបចំទិសដៅយុទ្ធសាស្ត្រ និងផែនការសកម្មភាពឱ្យប្រទាក់ក្រឡា និងស៊ីសង្វាក់គ្នា ដើម្បី ធានាការគាំទ្រ និងបំពេញឱ្យគ្នាទៅវិញទៅមកប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាព ទើបអាចធានាការ សម្រេចបានជោគជ័យនៃកំណែទម្រង់នីមួយៗបាន។

**ក.វិស័យរដ្ឋបាលទូទៅ**

បន្តគាំទ្រដល់ការលើកកម្ពស់ប្រសិទ្ធភាពការងារគ្រប់គ្រងចំណូល និងប្រមូលសារពើពន្ធ បន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ បន្តគាំទ្រទម្រង់វិស័យដីធ្លី បន្តគាំទ្រ និងពង្រឹងគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្ម បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងអំពើពុករលួយ បន្តគាំទ្រដល់ការ

លើកកម្ពស់ប្រសិទ្ធិភាពនៃកិច្ចការទូត គាំទ្រដល់ការត្រៀមរៀបចំដំណើរការបោះឆ្នោតឃុំសង្កាត់ គាំទ្រដល់ការរៀបចំធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំអាស៊ី អឺរ៉ុប។

**ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ**

បានបន្តការគាំទ្រដល់ការពង្រីកសមត្ថភាពរបស់នគរបាល និងកងកម្លាំងប្រដាប់អាវុធ បន្តផ្តោតលើការយកចិត្តទុកដាក់លើជីវភាព និងសុខុមាលភាពកងកម្លាំងប្រដាប់អាវុធ ជាមួយការគាំទ្រដល់កិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងរដ្ឋបាល បន្តគាំទ្រកិច្ចដំណើរការរដ្ឋបាល និងអន្តរាគមន៍ផ្សេងៗមួយវិញទៀតបន្តគាំទ្រកិច្ចដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ បន្តគាំទ្រដល់ការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព បន្តគាំទ្រដល់ប្រព័ន្ធត្រួតពិនិត្យសន្តិសុខតាមច្រកព្រំដែននិងផលិតលិខិតឆ្លងដែនបន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សស្ត្រី និងកុមារក៏ដូចជាការចូលរួមបន្តដល់ការប្រយុទ្ធប្រឆាំងគ្រឿងញៀនក្នុងសង្គម និងនៅតែបន្តគាំទ្រសេវាឥតគិតថ្លៃរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

**គ.វិស័យសង្គមកិច្ច**

មានការជំរុញឱ្យបន្តគាំទ្រការប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ បន្តគាំទ្រដល់ការលើកកម្ពស់គុណភាព និងគាំទ្រសេវាសុខាភិបាល បន្តគាំទ្រដល់ការពង្រឹងគុណភាព និងគាំទ្រសេវាអប់រំ គាំទ្រដល់ការអភិវឌ្ឍជំនាញ និងវិស័យការងារ បន្តគាំទ្រដល់ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ បន្តឧបត្ថម្ភគាំទ្រដល់សមាគមអតីតយុទ្ធជន បន្តឧបត្ថម្ភដល់មជ្ឈមណ្ឌលស្តារនីតិសម្បទាតាមបណ្តារាជធានី-ខេត្ត និងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា បន្តផ្តល់ថវិកាគាំទ្រដល់ការដោះស្រាយជីវភាពចំពោះជនក្រីក្រ និងចាស់ជរាតាមសហគមន៍ បន្តដល់ការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ បន្តដល់ការដល់ការពារ និងអភិរក្សធនធានធម្មជាតិ បន្តគាំទ្រដល់ការអភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ បន្តគាំទ្រដល់សុខដុមនីយកម្មសាសនា។

**ឃ.វិស័យសេដ្ឋកិច្ច**

បន្តគាំទ្រដល់ការលើកកម្ពស់បច្ចេកទេសកសិកម្ម និងសុវត្ថិភាពចំណីអាហារ គាំទ្រដល់ការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច ការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងជលផល បន្តគាំទ្រដល់ការពង្រឹងប្រសិទ្ធភាព និងការគ្រប់គ្រងធនធានរ៉ែគ្រប់ប្រភេទ បន្តគាំទ្រដល់ការអភិវឌ្ឍទឹកស្អាត និងអនាម័យជនបទ បន្តគាំទ្រដល់ការជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រ ជំរុញការអភិវឌ្ឍផលិតផល និងពង្រឹងសេវាទេសចរណ៍ បន្តបើកទីផ្សារសម្រាប់ការនាំចូលរបស់កម្ពុជា បន្តគាំទ្រដល់ការជួសជុលថែទាំផ្លូវ ស្ពាន និងផ្លូវលំជនបទព្រមទាំងស្តារស្រះ ជីកស្រះ និងអណ្តូងទឹក ដើម្បីទប់ទល់និងគ្រោះរាំងស្ងួត គាំទ្រដល់ការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ បន្តគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិច បន្តគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធនតូច និងមធ្យម និងអភិវឌ្ឍប្រព័ន្ធស្តង់ដា និងមាត្រាសាស្ត្រ។

**ង.ចំណាយផ្សេងៗ**

ការបន្តគាំទ្រការថែទាំសុខភាពសម្រាប់កម្មករ ការបន្តការឧបត្ថម្ភមាតុភាពសម្រាប់កម្មករនិយោជិត

ការបន្តនិរន្តរភាពមន្ទីរពេទ្យគន្ធបុប្ផា ការបន្តសកម្មភាពរាជរដ្ឋាភិបាលក្នុងការចុះសួរសុខទុក្ខកម្មករ កម្មការិនីនិង កម្មវិធីផ្ទេរសាច់ប្រាក់សម្រាប់ស្ត្រីក្រីក្រមានពោះធំ និងកុមារតូច។

### ២.២.២.កិច្ចលទ្ធកម្ម

នៅប្រទេសកម្ពុជារាល់សកម្មភាពទិញទំនិញ សាងសង់ ជួសជុល ការជួលសេវា និងការប្រឹក្សា ដោយរាជរដ្ឋាភិបាលបណ្តាក្រសួង និងទីភ្នាក់រាជរដ្ឋាភិបាលត្រូវធ្វើឡើងស្របតាម ច្បាប់ស្តីពីលទ្ធកម្ម សាធារណៈឆ្នាំ២០១២។ នីតិវិធីសម្រាប់វិធីសាស្ត្រដោយឡែកនៃលទ្ធកម្មសាធារណៈត្រូវបានប្បញ្ញត្តិនៅក្នុង អនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈ ឆ្នាំ២០០៦។ លទ្ធកម្មសាធារណៈមានទិសដៅធានាថាចំណាយរបស់រដ្ឋ ត្រូវបានគ្រប់គ្រងដោយមានប្រសិទ្ធភាព និងប្រសិទ្ធផល និងត្រូវបានត្រួតពិនិត្យដោយដំណើរការប្រកបដោយ តម្លាភាព យុត្តិធម៌ និងសំចៃពេលវេលា។

លទ្ធកម្មសាធារណៈអាចធ្វើឡើងតាមវិធីសាស្ត្រផ្សេងៗពីគ្នា។ វិធីសាស្ត្រនៃលទ្ធកម្មសាធារណៈត្រូវចាត់ថ្នាក់ជាៈការដេញថ្លៃដោយការប្រកួតប្រជែងអន្តរជាតិ ការដេញថ្លៃដោយការប្រកួតប្រជែងក្នុងស្រុកការប្រឹក្សាតម្លៃ និងការស្ទង់តម្លៃទៅតាមទីផ្សារជាក់ស្តែង។

ដូច្នេះ គ្រប់លទ្ធកម្មទាំងអស់ ត្រូវធ្វើឡើងតាមវិធីសាស្ត្រណាមួយ ក្នុងចំណោមពិធីសាស្ត្រខាងលើនេះ។ តម្លៃអប្បបរមាសម្រាប់ការដេញថ្លៃ ប្រភពធនធាន (សេវានិងទំនិញ) ក្នុងស្រុក និងសមត្ថភាពបច្ចេកទេស គឺជាកត្តាកំណត់អីពីការអនុវត្តវិធីសាស្ត្រនីមួយៗនៃលទ្ធកម្មសាធារណៈ។

តម្លៃសម្រាប់វិធីសាស្ត្រនីមួយៗនៃលទ្ធកម្មសាធារណៈ មានការប្រែប្រួល ពីរដ្ឋបាលថ្នាក់ជាតិ ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ឧទាហរណ៍ ខណៈដែលតម្លៃលើការដេញថ្លៃដោយការប្រកួតប្រជែងជាអន្តរជាតិ នៅតាមបណ្តាក្រសួង រាជធានី ខេត្ត និងស្ថាប័នសាធារណៈដទៃទៀត ត្រូវមានចាប់ពី ៥ ប៊ីលានរៀល តម្លៃការដេញថ្លៃដោយប្រើវិធីសាស្ត្រដូចគ្នា នៅរដ្ឋបាលក្រុង ស្រុក និងខណ្ឌគឺទាបជាង ចាប់ពី ២ប៊ីលានរៀល។ នៅក្នុងក្របខណ្ឌនៃតម្លៃដេញថ្លៃច្បាប់ហាមឃាត់រាល់ការអង្គន់តម្លៃដេញថ្លៃជាចំណែកតូចៗ ដើម្បីជៀសវាង ការអនុវត្តវិធីសាស្ត្រពាក់ព័ន្ធនៃលទ្ធកម្មសាធារណៈ ដោយមានជាទណ្ឌកម្ម។

រាល់លទ្ធកម្មសាធារណៈត្រូវរៀបចំដោយគណៈកម្មាធិការលទ្ធកម្មសាធារណៈ នៅតាមស្ថាប័នអនុវត្ត លទ្ធកម្មសាធារណៈ។ ស្ថាប័នអនុវត្តលទ្ធកម្មសាធារណៈរួមមាន ក្រសួង រដ្ឋាភិបាល ស្ថាប័នជាតិ សហគ្រាស សាធារណៈ គ្រឹះស្ថានសាធារណៈ និងរដ្ឋបាលក្រោមជាតិ។ ទោះបីជាយ៉ាងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងលទ្ធកម្មសាធារណៈ។ រាល់សកម្មភាពនៃលទ្ធកម្មសាធារណៈត្រូវឆ្លង សវនកម្ម និងអធិការកិច្ចនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

អង្គភាពអនុវត្តលទ្ធកម្ម នៃស្ថាប័នពាក់ព័ន្ធ ត្រូវប្រកាសផ្សាយព័ត៌មានអំពីការដេញថ្លៃ ជាសាធារណៈ។ ចាប់តាំងពីខែកុម្ភៈឆ្នាំ២០១១មកព័ត៌មានស្តីពីការដេញថ្លៃដោយការប្រកួតប្រជែងជាអន្តរជាតិ និងការដេញថ្លៃ ដោយការប្រកួតប្រជែងក្នុងស្រុកត្រូវបានប្រកាសផ្សាយនៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សេចក្តីប្រកាសព័ត៌មានអំពីការដេញថ្លៃនៅក្រោមគម្រោងរបស់ឃុំ-សង្កាត់ អាចរកមើលបាននៅលើគេហទំព័រ

របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ព័ត៌មានទាំងនេះក៏អាចរកបាននៅតាមបណ្តាក្រសួង និងស្ថាប័នរដ្ឋដូចជាគេហទំព័ររបស់ ក្រសួងអប់រំយុវជននិងកីឡា ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណការ និងដឹកជញ្ជូន និង ច្រកចេញចូលតែមួយ។

បណ្តឹងអំពីភាពមិនប្រក្រតីនៃការដេញថ្លៃដោយបុគ្គលនិងក្រុមហ៊ុនចូលរួមដេញថ្លៃ អាចធ្វើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនិងអធិការកិច្ច។ ក្នុងករណីមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ក្រសួងបណ្តឹងអាចធ្វើឡើងនៅចំពោះមុខ អង្គភាពប្រឆាំងអំពើពុករលួយ ឬដោយផ្ទាល់ទៅតុលាការ។ បន្ទាប់ពីបានទទួលបណ្តឹង ប្រធាន អនុប្រធាន និងមន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ បំពេញតួនាទីភារកិច្ចជានគរបាលយុត្តិធម៌ដោយបើកការស៊ើបអង្កេតលើបណ្តឹង និងបញ្ជូនរបាយការណ៍ស្តីពីការស៊ើបអង្កេតនោះ ទៅព្រះរាជអាជ្ញា និងតុលាការ។

ភាពមិនប្រក្រតីនៃលទ្ធកម្មសាធារណៈ កើតមានជាធម្មតាជាមួយនឹងក្រសួង និងស្ថាប័នរដ្ឋ។ បើទោះជាប្រទេសកម្ពុជា មានច្បាប់តឹងតែងស្តីពីលទ្ធកម្មសាធារណៈ ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងក្រមព្រហ្មទណ្ឌយូរមកហើយក៏ដោយវាហាក់បីដូចជាមិនមានចំណាត់ការដាក់លាក់ណាមួយ ប្រឆាំងនឹងការអនុវត្តមិនត្រឹមត្រូវនៅឡើងទេ។ ឧទាហរណ៍អង្គភាពរដ្ឋចំនួនបី រួមមានអគ្គនាយកដ្ឋានប្រៃសណីយ៍នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ប្រៃសណីយ៍កម្ពុជា និងកំពង់ផែស្វយ័តភ្នំពេញ ជាប់សង្ស័យពីការអនុវត្តមិនត្រឹមត្រូវតាមនីតិវិធីនៃលទ្ធកម្មសាធារណៈ។ នៅក្នុងបណ្តាភាពមិនប្រក្រតីដែលត្រូវបានរាយការណ៍ករណីរបស់ក្រសួងសុខាភិបាល បានទាក់ទាញការចាប់អារម្មណ៍របស់ប្រព័ន្ធផ្សព្វផ្សាយយ៉ាងខ្លាំង។

## ២.៣.ការធ្វើវិចារណកម្មចំណាយថវិកាថ្នាក់ជាតិ

ការធ្វើវិចារណកម្មចំណាយថវិកាឆ្នាំ២០២១ ត្រូវបានលើកលែងសម្រាប់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ ដែលកំពុងមានភារកិច្ចច្រើនក្នុងដំណាក់កាលប្រយុទ្ធប្រឆាំងនឹងការរាតត្បាតជំងឺកូវីដ១៩ ព្រមទាំងផ្តល់ការលើកលែងវិចារណកម្មថវិកាចំណាយចរន្តរបស់ក្រសួងសុខាភិបាល ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ (ផ្នែកសន្តិសុខសាធារណៈ) ដែលបាន និងកំពុងចូលរួមផ្ទាល់ក្នុងសកម្មភាពទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ១៩ ព្រមទាំងផ្តល់ភាពទន់ភ្លន់ដល់ក្រសួងទាំង៣នេះ អាចធ្វើនិយ័តកម្មឥណទានផ្ទៃក្នុងឱ្យអស់លទ្ធភាពតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន ដើម្បីបំពេញតម្រូវការចាំបាច់ផ្នែកអន្តរាគមន៍ដែលពាក់ព័ន្ធនឹងវិបត្តជំងឺកូវីដ១៩ ដើម្បីជៀសវាងនូវការស្នើសុំបន្ថែមឥណទាន។

### ២.៣.១.ចំណាយចរន្តថវិកាថ្នាក់ជាតិ

វិធានការនៃការធ្វើវិចារណកម្មចំណាយចរន្តថ្នាក់ជាតិនេះ ត្រូវបានដាក់ឲ្យអនុវត្តលើចំណាយមិនមែនបន្ទុកបុគ្គលិកដោយកាត់ព្យួរចំណាយទៅតាមកម្រិតនៃភាគរយដែលបានកំណត់លើមូលដ្ឋានឥណទានថវិកា ៥០% នៃឥណទានអនុម័តដោយស្របច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ចំពោះមុខសញ្ញាចំណាយមួយចំនួនដែលមិនទាន់ចាំបាច់ ឬមិនចាំបាច់ខ្លាំង និងមិនសូវប៉ះពាល់សកម្មភាពការងាររបស់ក្រសួងស្ថាប័ន តាមគោលការណ៍ដូចខាងក្រោម៖

**ក. ក្រសួង ស្ថាប័នរដ្ឋបាលកណ្ដាល**

កាត់ព្យួរចំណាយ៥០%លើឥណទានថវិកា៥០% នៃឥណទានអនុម័ត (ស្មើនឹងកាត់សន្សំ២០% នៃឥណទានអនុម័ត)លើមុខសញ្ញាចំណាយរួមមាន៖ (១)សម្ភារៈការិយាល័យ (២)សម្ភារៈប្រើប្រាស់ (៣) សម្ភារៈ និងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា និង (៤) សម្ភារៈ និងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា។ កាត់ព្យួរចំណាយ៧៥%លើឥណទានថវិកា ៥០%នៃឥណទានអនុម័ត(ស្មើនឹងកាត់សន្សំ៣៧,៥% នៃឥណទាន អនុម័ត) លើមុខសញ្ញាចំណាយរួមមាន៖ (១)សង្ហារឹម (២)សោហ៊ុយបណ្ដុះបណ្ដាលក្នុង និងក្រៅប្រទេស, (៣)សោហ៊ុយទទួលភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិ (៤)សោហ៊ុយទទួលភ្ញៀវជាតិ និងភ្ញៀវបរទេស (៥)ប្រជុំសិក្ខា សាលា និងសន្និសិទ (៦)វត្ថុអនុស្សាវរីយ៍ក្នុង និងក្រៅប្រទេស(៧) ការតាំងពិពណ៌នៅក្នុង និងក្រៅប្រទេស, (៨)ការឃោសនានិងផ្សព្វផ្សាយ (៩)បេសកម្មក្នុងប្រទេស (១០)ការរៀបចំពិធីបុណ្យ និង(១១) ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រសាទ។ កាត់ព្យួរចំណាយ ១០០% លើឥណទានថវិកា ៥០% នៃឥណទានអនុម័ត (ស្មើនឹងកាត់សន្សំ ៥០%នៃឥណទានអនុម័ត) លើមុខសញ្ញាចំណាយ រួមមាន៖ (១)ឯកសណ្ឋាន និង (២) បេសកកម្មក្រៅប្រទេស។ កាត់ព្យួរចំណាយ១០០%លើឥណទានថវិការ៥០%នៃឥណទានអនុម័ត (ស្មើនឹងកាត់សន្សំ៥០%នៃឥណទានអនុម័ត) លើប្រេងឥន្ធនៈ និងប្រេងរំអិល។ សម្រាប់ក្រសួងស្ថាប័ន និងអង្គភាព ដែលទទួលបានធានាចំណាយរួចហើយ តែមិនទាន់បានចុះកិច្ចសន្យា ត្រូវបង្កកធានាចំណាយចំនួន៥០%។ ដោយឡែកចំពោះក្រសួង ស្ថាប័ន និងអង្គភាពដែលបានចុះកិច្ចសន្យារួចហើយ ត្រូវបានបង្កកបរិមាណប្រេងឥន្ធនៈ និងប្រេងរំអិល ចំនួន៥០% នៅនឹងក្រុមហ៊ុនផ្គត់ផ្គង់តែម្តង។

ចំពោះឥណទានដែលអនុវត្តសល់បន្ទាប់ពីការកាត់សន្សំ តាមគោលការណ៍ខាងលើរួចហើយមិនត្រូវបានអនុញ្ញាតឱ្យធ្វើនិយ័តកម្មទៅប្រើលើមុខចំណាយផ្សេងឡើយ លើកលែងតែមានការសម្រេចដោយឡែករបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់អនុវត្តសកម្មភាពអាទិភាពខ្ពស់បំផុតរបស់រាជរដ្ឋាភិបាល។

ផ្អែកលើគោលការណ៍កាត់ព្យួរឥណទានខាងលើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងរៀបចំជាតារាងឧបសម្ព័ន្ធជូនទៅក្រសួង-ស្ថាប័ន និងគ្រឹះស្ថានសាធារណៈរដ្ឋបាលពាក់ព័ន្ធអំពីទំហំឥណទាន ដែលត្រូវបានធ្វើវិចារកម្មចំណាយ និងឥណទានដែលនៅមានសម្រាប់បន្តបញ្ជាចំណាយបាន។ លើមូលដ្ឋាននេះ ក្រសួង ស្ថាប័ន និងគ្រឹះស្ថានសាធារណៈរដ្ឋបាលពាក់ព័ន្ធទាំងអស់ចាំបាច់ត្រូវតែតម្រូវទំហំឥណទានសរុបរួមទាំងតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានរបស់ខ្លួន ទៅតាមទំហំនៃមុខសញ្ញាចំណាយទាំងអស់ដែលបានកាត់សន្សំព្យួរខាងលើ និងទៅតាមកម្មវិធី និងចង្កោមសកម្មភាពពាក់ព័ន្ធ។

**ខ. គ្រឹះស្ថានសាធារណៈរដ្ឋបាល**

គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលទទួលឧបត្ថម្ភធន ១០០% ពីថវិកាថ្នាក់ជាតិ ត្រូវបានកាត់ព្យួរឥណទានតាមគោលការណ៍សន្សំចំណាយ ដូចអនុវត្តចំពោះក្រសួង ស្ថាប័នថ្នាក់កណ្តាលដែរ ប៉ុន្តែផ្តល់ការលើកលែងចំពោះមុខចំណាយជួសជុល និងថែទាំប្រាសាទរបស់ អាជ្ញាធរជាតិអប្សរា អាជ្ញាធរព្រះវិហារ និងអាជ្ញាធរសំបូរព្រៃគុក។ ដោយឡែក ចំពោះគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលទទួលបានឧបត្ថម្ភធនពីថវិកាថ្នាក់ជាតិមួយផ្នែកសម្រាប់បំពេញតុល្យភាពចំណូល-ចំណាយប្រចាំឆ្នាំ ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ថវិកាក្នុងកម្រិតតុល្យភាពរបស់ខ្លួន ប៉ុន្តែនឹងមិនមានការបន្ថែមឥណទានថវិកាជូនទេ។ ក្នុងករណីចំណូលផ្ទាល់មានការថយចុះ។

**គ. អង្គភាពជាក្រុមប្រឹក្សា អាជ្ញាធរ និងគណៈកម្មាធិការរបស់រដ្ឋាភិបាល**

ចំពោះអង្គភាពដែលជាក្រុមប្រឹក្សាអាជ្ញាធរ និងគណៈកម្មាធិការនានារដ្ឋាភិបាល ដែលមានកញ្ចប់ថវិកាស្ថិតនៅក្រោមក្រសួងស្ថាប័នពាក់ព័ន្ធ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងពិនិត្យប្រសិទ្ធភាពចំណាយ ដើម្បីសន្សំ និងបង្កកមុខចំណាយជាក់ស្តែងទៅតាមលំនាំនៃគោលការណ៍ខាងលើ នៅពេលអង្គភាពនីមួយៗស្នើសុំចំណាយមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**២.៣.២. ចំណាយមូលធនថវិកាថ្នាក់ជាតិ**

ក្នុងគោលដៅនៃការរួមចំណែកដល់ការសន្សំធនធាន ដើម្បីបង្វែរមកដោះស្រាយបញ្ហាជាអាទិភាពនាពេលបច្ចុប្បន្នក្នុងបរិការណ៍នៃវិបត្តិជំងឺកូវីដ១៩ ឥណទានព្យួរចំនួនប្រមាណ១១% នៃកញ្ចប់ឥណទានរួមដែលបានវិភាជន៍ជូនក្រសួងអាទិភាពចំនួន៧ (ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណៈការ និងដឹកជញ្ជូន ក្រសួងធនធានទឹក និងឧត្តុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដីនគររូបនីយកម្មនិងសំណង់) និងក្រសួងស្ថាប័នផ្សេងៗ ព្រមទាំងមុខសញ្ញាចំណាយត្រៀមបម្រុងនានាដែលប្រើកញ្ចប់ឥណទានមិនទាន់បែងចែកប្រចាំឆ្នាំរបស់រដ្ឋាភិបាល។

ជាមួយនឹងការកាត់សន្សំខាងលើនេះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងផ្អាកការផ្តល់នានា ចំណាយសម្រាប់គម្រោងត្រៀមបម្រុងរបស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧត្តុនិយម។ ក្នុងករណីចាំបាច់សម្រាប់គម្រោងថ្មី និងគម្រោងទួលបានការសម្រេចរួចហើយដែលមានចរិកទ្រទ្រង់ដង្ហើមសេដ្ឋកិច្ចក្នុងស្រុក គម្រោងស្តារឡើងវិញដែលខូចខាតដោយទឹកជំនន់ពីឆ្នាំ២០២០ គម្រោងពហុឆ្នាំដែលផ្តល់ផលប្រយោជន៍សេដ្ឋកិច្ច និងគម្រោងហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល ត្រូវបានផ្តល់អាទិភាពក្នុងការស្នើសុំការសម្រេចដោយឡែកទៅតាមករណី និងតាមលទ្ធភាពថវិកាជាក់ស្តែង។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងរៀបចំជាតារាងឧបសម្ព័ន្ធជូនទៅក្រសួងពាក់ព័ន្ធទាំង៧ អំពីទំហំឥណទានដែលត្រូវបានធ្វើវិចារណកម្មចំណាយ និងឥណទានដែលនៅមានសម្រាប់បន្តបញ្ជាចំណាយបាន។ លើមូលដ្ឋាននេះក្រសួងទាំង៧ខាងលើដែលទទួលបានឥណទានវិនិយោគសាធារណៈជាប្រចាំ ចាំបាច់ត្រូវធ្វើអាទិភាវូបនីយកម្មគម្រោងឡើងវិញទៅតាមកម្រិតឥណទានថវិកាដែលនៅមាន។

**២.៣.៣. ការជំរុញ និងពង្រឹងប្រសិទ្ធភាពចំណាយ**

ពង្រឹងប្រសិទ្ធភាពប្រតិបត្តិការចំណាយទាំងការលើកកម្ពស់តម្លៃលុយថាប្រភេទបរិមាណ និងទាំងប្រសិទ្ធិភាពបច្ចេកទេស។ ទប់ស្កាត់ចំណាយដែលមិនចាំបាច់ ឬដែលមិនមានផលចំណេញ ឬមិនមានផលប្រយោជន៍ច្បាស់លាស់ សម្រាប់ក្រសួង-ស្ថាប័នសម្រេចគោលដៅបេសកកម្មការងាររបស់ខ្លួន។ រឹតបណ្តឹងចំណាយនៅតាមក្រសួង-ស្ថាប័ននីមួយៗដែលមិនមានផលដល់ការជំរុញការប្រើប្រាស់ក្នុងស្រុក។ ផ្អាកការទិញសម្ភារឧបករណ៍មិនបន្ទាន់ និងដែលមានចរិកជាការនាំចូល ព្រមទាំងផ្អាកការផ្តល់គោលការណ៍ជួសជុលថ្មីៗលើកលែងតែការាចជួសជុលអគារដែលមានស្រាប់។

សម្រួលការអនុវត្តចំណាយឲ្យបានលឿនជាពិសេសចំណាយការការពារ និងប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ ចំណាយដើម្បីស្រូបយកការប៉ះពាល់ចំណាយអន្តរាគមន៍ទ្រទ្រង់សកម្មភាពសេដ្ឋកិច្ច ដើម្បីឆ្លើយតបឲ្យបានសមស្របទៅនឹងសភាពការណ៍វិវត្តន៍ជាក់ស្តែងឱ្យបានទាន់ពេលវេលា។

ការធ្វើវិចារណកម្មនេះ និងការពង្រឹងប្រសិទ្ធភាពចំណាយដែលបានដាក់ចេញខាងលើត្រូវបានគិតគូររៀបចំឡើងក្នុងក្របខណ្ឌនៃការធានាប្រក្រតីភាពនៃស្ថាប័នរដ្ឋ និងរក្សាលំនឹងជីវភាពប្រជាជន ទន្ទឹមនឹងការសន្សំធនធានថវិកាដើម្បីបង្វែរទៅបំពេញឱ្យសេដ្ឋកិច្ចត្រូវការចាំចាច់ និងបន្ទាន់របស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងការរាតត្បាតនៃជំងឺកូវីដ១៩ ពិសេសក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់នៅទីតាំងភូមិសាស្ត្រមួយចំនួនដើម្បីបង្កើនសុវត្ថិភាពនិងដោះស្រាយជីវភាពជូនប្រជាពលរដ្ឋគ្រប់រូប ជាពិសេសគ្រួសារក្រក្រី និងជនងាយរកគ្រោះ។

គ្រប់ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាលពាក់ព័ន្ធ និងអង្គភាពក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាព។ ក្រោយពីទទួលបានកម្មវិធីចំណូល-ចំណាយដែលស្នើឡើងដោយក្រសួង-ស្ថាប័ននិងមន្ទីរជំថវិកានាញរាជធានី-ខេត្តក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រួតពិនិត្យនិងវាយតម្លៃលើអាទិភាពនៃតម្រូវការនិងលទ្ធភាពចំណូលដែលអាចប្រមូលបាន ដើម្បីដាក់ចេញជាកម្មវិធីចំណូល ចំណាយប្រចាំត្រីមាស ទៅតាមមាតិកាថវិកាសម្រាប់អនុវត្ត។

ការរៀបចំកម្មវិធីចំណូលចំណាយប្រចាំត្រីមាសឱ្យកាន់តែបានត្រឹមត្រូវ និងសុក្រឹតព្រមទាំងការអនុវត្តឱ្យបានម៉ឹងម៉ាត់តាមកម្មវិធីចំណូល-ចំណាយនេះគឺជាប្រការចាំបាច់បំផុត។ដូច្នេះគ្រប់ក្រសួងស្ថាប័នមន្ទីរជំនាញរាជធានី ខេត្តក្រោមឱវាទទាំងអស់ អគ្គនាយកដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តឱ្យបានម៉ឹងម៉ាត់នូវអភិក្រមការងារដូចខាងក្រោម៖

**ក. ការរៀបចំកម្មវិធីចំណូល ចំណាយប្រចាំត្រីមាស**

អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកដ្ឋានហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ និងមន្ទីរសេដ្ឋកិច្ចនិ ងហិរញ្ញវត្ថុព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវផ្ញើមកអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិនូវរបាយការណ៍ប៉ាន់ស្មាន ការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ដែលកំពុងអនុវត្តដោយឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងប្រចាំខែទី១

និងខែទី២ និងការប៉ាន់ស្មានការអនុវត្តខែទី៣ ជាមួយនឹងការស្នើឡើងនូវការកែសម្រួលគម្រោងកម្មវិធីចំណូលចំណាយប្រចាំត្រីមាសបន្ទាប់ នៅរៀងរាល់ថ្ងៃទី២០ នៃខែ នាចុងត្រីមាសនីមួយៗ។

មន្ទីរជំនាញរាជធានី ខេត្តក្រោមឱវាទទាំងអស់ ត្រូវផ្ញើរបាយការណ៍ប៉ាន់ស្មានការអនុវត្តកម្មវិធីចំណូលចំណាយប្រចាំត្រីមាសកំពុងអនុវត្តដោយឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងប្រចាំខែទី១ និងខែទី២ និងការប៉ាន់ស្មានអនុវត្តខែទី៣ ជាមួយនឹងការស្នើឡើងនូវការកែសម្រួលគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសបន្ទាប់ទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី១៥នៃខែនាចុងត្រីមាសនីមួយៗ ដើម្បីទុកពេលវេលាឲ្យមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុបូកសរុបរួមផ្ញើមកអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី២០ នៃខែនាចុងត្រីមាសនីមួយៗ។

អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចរៀបចំប្រជុំពិភាក្សាតាមការចាំបាច់ជាមួយនឹងនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាអគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីរៀបចំកម្មវិធីចំណូល-ចំណាយថវិកាថ្នាក់ជាតិសម្រាប់ត្រីមាសបន្ទាប់ នៅរៀងរាល់ថ្ងៃទី២៥ នៃខែ នាចុងត្រីមាសនីមួយៗ។ ផ្អែកលើមូលដ្ឋាននៃកម្មវិធី ចំណូលចំណាយនេះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានថវិកា)ត្រូវរៀបចំប្រកាសកម្មវិធីចំណូល-ចំណាយសម្រាប់ត្រីមាសបន្ទាប់ ទៅតាមមាតិកាក្នុងកម្រិតឥណទានថវិកាអតិបរមាសម្រាប់ក្រសួង ស្ថាប័ននីមួយៗនឹងមន្ទីរជំនាញរាជធានីខេត្តក្រោមឱវាទនីមួយៗ ដោយចម្លងជូនអគ្គនាយកដ្ឋានរតនាគារជាតិ។

### ខ. ការអនុវត្តកម្មវិធីចំណូល ចំណាយប្រចាំត្រីមាស

អាណាប័កដើមខ្សែ ឬអាណាប័កផ្ទេរសិទ្ធិ ត្រូវចេញអាណត្តិបើកប្រាក់នៅក្នុងរង្វង់នៃកម្មវិធីចំណាយប្រចាំត្រីមាសរបស់ខ្លួនហើយ អគ្គនាយកដ្ឋានថវិកាមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត រតនាគារថ្នាក់កណ្ដាល និងរតនាគាររាជធានី-ខេត្តត្រូវចុះទិដ្ឋការលើអាណត្តិបើកប្រាក់ និងត្រួតពិនិត្យទូទាត់ និងបើកសាច់ប្រាក់តែនៅក្នុងកម្រិតនៃកម្មវិធីចំណូល-ចំណាយថវិកា និងសាច់ប្រាក់ប្រចាំត្រីមាសនេះតែប៉ុណ្ណោះ។ ក្នុងករណីដែលអាណត្តិបើកប្រាក់លើសពីរង្វង់នៃកម្មវិធីចំណាយប្រចាំត្រីមាស ក្រសួងស្ថាប័ន និងមន្ទីរជំនាញរាជធានីខេត្តក្រោមឱវាទ ត្រូវធ្វើសំណើរសុំបន្ថែមកម្មវិធីចំណាយមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[1]

## ២.៤.ទិសដៅ និងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ជាតិ

ការកែទម្រង់រដ្ឋបាលសាធារណៈនៅកម្ពុជាទទួល បាននូវលទ្ធផលល្អជាងមុនមួយកម្រិតក៏ពិតមែន ប៉ុន្តែក៏មានបញ្ហាប្រឈមមួយចំនួនដែលរាំងស្ទះដល់ការងារទម្រង់នេះ។ដូច្នេះយើងខ្ញុំសូមចូលរួមជាអនុសាសន៍មួយចំនួនដើម្បីឱ្យការកែទម្រង់រដ្ឋបាលសាធារណៈកាន់តែល្អប្រសើរជាងនេះមួយកម្រិតទៀត ៖

[1] សារាចរណ៍ណែនាំស្តីពី ការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធិភាពចំណាយថវិកាថ្នាក់ជាតិ ឆ្នាំ២០២១ យោងប្រកាសលេខ១២០៤ សហវ.ប្រក ចុះថ្ងៃអង្គារ ១៥កើត ខែបុស្ស ឆ្នាំជូត ទោសស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២

បន្តពង្រឹងគុណភាពសេវាសាធារណៈតាមរយៈការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលខ្វះខាត ការកែលម្អនីតិវិធីក្នុងការផ្តល់សេវាដើម្បីឱ្យកាន់តែងាយស្រួលទៅ និងឆាប់រហ័សជាងមុន។

ជំរុញឱ្យមាននូវចលនាប្រកួតប្រជែងក្នុងការផ្តល់សេវាសាធារណៈលើគ្រប់វិស័យ ព្រោះបច្ចុប្បន្នអនុវត្តបានតែក្នុងវិស័យអទិភាពរបស់រាជរដ្ឋាភិបាលជំរុញ និងបង្កើនវិសាលភាពក្នុងការផ្តល់សេវាសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យានិងបន្តការផ្សព្វផ្សាយបន្ថែមពីប្រភេទសេវានិងក្រសួងស្ថាប័នដែលធ្វើកិច្ចការនេះ បន្តជំរុញឱ្យមានការរៀបចំការពិពណ៌នាមុខតំណែងនៅគ្រប់ក្រសួងស្ថាប័ន ដើម្បីកាត់បន្ថយការជាន់តួនាទីភារកិច្ចក៏ដូចជាស្វែងយល់ពីបន្ទុកការងាររបស់មន្ត្រីបុគ្គលិកតាម ក្រសួង-ស្ថាប័ននីមួយៗឱ្យកាន់តែច្បាស់លាស់ជំរុញការផ្សព្វផ្សាយពីកម្មវិធីជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការងារកែទម្រង់រដ្ឋបាលសាធារណៈឱ្យកាន់តែទូលំទូលាយដល់សាធារណជនពិសេសមន្ត្រីរាជការដែលបំពេញការងារតាមក្រសួង ស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងដៃគូរអភិវឌ្ឍនានាបន្តពង្រឹងសមត្ថភាពធនធានមនុស្ស ដើម្បីឱ្យធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈមានសមត្ថភាពគ្រប់គ្រាន់ក្នុងការឆ្លើយតបនឹងតម្រូវការរបស់រាជរដ្ឋាភិបាល តាមរយៈការបង្កើនចំនួនបណ្តុះបណ្តាល និងបង្កើនគុណភាពក្នុងការបណ្តុះបណ្តាលត្រូវសិក្សា និងដកស្រង់បទពិសោធន៍វិធីសាស្ត្របណ្តុះបណ្តាលធនធានមនុស្សពីសាលាភូមិន្ទរដ្ឋបាល ព្រោះសាលានេះជាគ្រឹះស្ថានសាធារណៈដែលមានការទទួលស្គាល់ពីគុណភាពក្នុងការបណ្តុះបណ្តាល។

ជំរុញការយល់ដឹងបន្ថែមពីចក្ខុវិស័យនៃកែទម្រង់និងការចូលរួមរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ បន្តបង្កើនបៀវត្សឱ្យកាន់តែល្អជាងមុនដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់មន្ត្រីរាជការ និងបុគ្គលិកនៅក្រោយពេលដែលស្ថានភាពសេដ្ឋកិច្ចកម្ពុជាមានភាពល្អប្រសើរវិញ។ តាមរយៈការសិក្សាខាងលើ យើងសង្កេតឃើញថាផ្តើមចេញពីចក្ខុវិស័យដែលចង់ប្រែក្លាយកម្ពុជាឱ្យក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ឆ្នាំ២០៣០ និងចំណូលខ្ពស់ក្នុងឆ្នាំ២០៥០ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ដែលជាក្របខណ្ឌគោលនយោបាយដ៏សំខាន់ក្នុងការសម្រេចបាននូវចក្ខុវិស័យនេះ។ នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលក៏បានកំណត់យកនូវការកែទម្រង់រដ្ឋបាលសាធារណៈជាការដ្ឋានមួយក្នុងចំណោមការដ្ឋានទាំង៤ដើម្បីសម្រេចបាននូវអភិបាលកិច្ចល្អដែលជាស្នូលនៃយុទ្ធសាស្ត្រនេះ។ ម៉្យាងទៀតដើម្បីឱ្យការងារកែទម្រង់រដ្ឋបាលសាធារណៈកាន់តែមានក្របខណ្ឌគោលនយោបាយច្បាស់ជាងនេះទៀតរាជរដ្ឋាភិបាលបានអនុម័តនូវកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈដែលមានចក្ខុវិស័យប្រែក្លាយរដ្ឋបាលសាធារណៈឱ្យទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព និងជាដៃគូអភិវឌ្ឍដែលអាចជឿទុកចិត្តបាន សំដៅបម្រើប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរ។

រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការកែទម្រង់រដ្ឋបាលសាធារណៈដោយផ្អែកលើបីចំណុចសំខាន់គឺ ការកែលម្អគុណភាពសេវាសាធារណៈ ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស និងការកែទម្រង់ប្រព័ន្ធបៀវត្ស។ តាមរយៈការអនុវត្តការងារពីឆ្នាំ២០១៥ មកដល់ដើមឆ្នាំ២០២០នេះ រាជរដ្ឋាភិបាលសម្រេចបាននូវលទ្ធផលជាច្រើនដូចជាការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន ការពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនិង

ស្ថាប័នការកែលម្អសេវាសាធារណៈ ការកែទម្រង់ប្រព័ន្ធបៀវត្សដើម្បីបង្កើនបៀវត្ស ប្រាក់ឧបត្ថម្ភនិងរបបសន្តិសុខសង្គមព្រមទាំងការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនានា។ ទន្ទឹមនឹងលទ្ធផលដែលសម្រេចការកែទម្រង់នេះក៏បានជួបប្រទះនូវបញ្ហាមួយចំនួនដែរដូចជា ធនធានមនុស្ស ថវិកា និងកង្វះខាតលិខិតគតិយុត្តក្នុងការជំរុញការអនុវត្ត ដែលវាជាបញ្ហាចោទដ៏សំខាន់ក្នុងការស្វែងរកដំណោះស្រាយ។ ឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះរាជរដ្ឋាភិបាលបាននិងកំពុងដាក់ចេញជាយុទ្ធសាស្ត្រ និងរៀបចំនូវកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០២០-២០៣០ ដែលផ្តោតលើការផ្តុំសមិទ្ធផលតូចៗបញ្ចូលគ្នាដើម្បីក្លាយជារូបភាពធំជាងនេះ និងជាក់ស្តែងនិយម ព្រមទាំងជំរុញការកែទម្រង់ឱ្យមានល្បឿនលឿន និងមានប្រសិទ្ធភាពជាងមុន។

ជារួមឃើញថា រាជរដ្ឋាភិបាលដែលមានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងក្រសួងមុខងារសាធារណៈជាសេនាធិការ បានខិតខំយ៉ាងខ្លាំងក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ដោយបានដាក់ចេញនូវគោលបំណង គោលដៅ យុទ្ធសាស្ត្រ និងសកម្មភាពយ៉ាងច្បាស់លាស់ និងតាមរយៈការជំរុញ តាមដាន និងសហការជាមួយក្រសួង ស្ថាប័ននានា រួមជាមួយដៃគូអភិវឌ្ឍ ការខិតខំនេះសម្រេចបាននូវលទ្ធផលគួរជាទីមោទនភាព ព្រោះសកម្មភាពទាំងឡាយដែលបានដាក់ចេញសុទ្ធតែបានបំពេញ ទោះបីមានសកម្មភាពខ្លះសម្រេចបានដោយផ្នែកក៏ដោយ។

### ២.៤.១.ការត្រួតពិនិត្យមើលលើការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ជាតិ

ក្នុងពេលបច្ចុប្បន្ន បន្ទាប់ពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈត្រូវបានកំណត់រួចរាជរដ្ឋាភិបាលចេញសារាចរណែនាំ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាជាតិ។ ផ្អែកលើសារាចរណែនាំនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចេញសារាចរណែនាំដោយឡែកមួយទៀតស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី-ខេត្ត។ ផែនការយុទ្ធសាស្ត្រថវិកាត្រូវបានរៀបចំនៅកម្រិតរាជធានី-ខេត្តដោយផ្អែកលើកម្មវិធី និងអាទិភាពនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងតម្រឹមជាមួយនឹងអាទិភាពជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដែលបានឆ្លុះបញ្ចាំងនៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរាជធានី-ខេត្តនីមួយៗ ផែនការយុទ្ធសាស្ត្រថវិការាជធានី-ខេត្តត្រូវបានដាក់ឱ្យក្រុមប្រឹក្សារាជធានី-ខេត្តពិនិត្យ និងអនុម័តសិន មុននឹងបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំ ដែលជាលទ្ធផលនៃការធ្វើសមាហរណកម្ម ផែនការអភិវឌ្ឍន៍នៃគ្រប់កម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ។ រដ្ឋបាលរាជធានី-ខេត្តបានរៀបចំផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងរយៈពេលប្រាំឆ្នាំម្តងដោយត្រូវដាក់ឱ្យក្រុមប្រឹក្សារាជធានីខេត្តពិនិត្យ និងអនុម័តមុនពេលបញ្ជូនទៅក្រសួងមហាផ្ទៃដើម្បីពិភាក្សា និងសម្រេច។ ផែនការអភិវឌ្ឍន៍ទាំងនោះត្រូវបានរៀបចំដាច់ដោយឡែកនិងដាក់ជូនក្រុមប្រឹក្សារៀងៗខ្លួនដើម្បីពិនិត្យនិងអនុម័តមុនពេលបញ្ជូនទៅរដ្ឋបាលរាជធានី-ខេត្តដើម្បីបូកសរុប។ផែនការអភិវឌ្ឍន៍ក្រុងស្រុក ខណ្ឌនិងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ មិនត្រូវបានបូកបញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានី-ខេត្តទេ។ បច្ចុប្បន្នការតម្រឹមផែនការកម្មវិធីតាមខ្សែទទឹងរវាងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ និងថវិកាមន្ទីរជំនាញរាជធានី ខេត្តនៅមិនទាន់បានធ្វើនៅ

ឡើយទេដោយសារតែពុំទាន់មានការប្រឹក្សាយោបល់គ្នា និងសហការគ្នាឱ្យបានគ្រប់គ្រាន់រវាងក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដូចនេះការប្រតិបត្តិបច្ចុប្បន្នមិនទាន់ផ្តល់ជាមូលដ្ឋាន សមាហរណកម្មល្អរវាងផែនការនីយកម្មនៃស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ។

គោលបំណងនៅឆ្នាំ២០២៥ គឺកែលម្អជាបណ្តើរៗនូវដំណើរការធ្វើផែនការយុទ្ធសាស្ត្រថវិការាជធានីខេត្តឱ្យមានលក្ខណៈសមាហរណកម្មដែលផ្សារភ្ជាប់គ្នាប្រកបដោយប្រសិទ្ធភាពរវាងផែនការកម្មវិធីនៃថវិកាថ្នាក់ក្រោមជាតិទៅនឹងអាទិភាពជាតិ/ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ការរៀបចំផែនការយុទ្ធសាស្ត្រ ថវិការាជធានី-ខេត្តនឹងផ្អែកទៅលើក្របខ័ណ្ឌថវិកាជាតិរយៈពេលមធ្យមដែលក្នុងនោះក៏មានការកំណត់ពិដានថវិកាសម្រាប់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់រាជធានី-ខេត្ត នីមួយៗ។ ផែនការយុទ្ធសាស្ត្រថវិការាជធានីខេត្តនឹងត្រូវបានធ្វើសមាហរណកម្មតាមខ្សែទទឹងសម្រាប់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ និងមានការតម្រឹមតាមខ្សែបណ្តោយជាមួយនឹងអាទិភាពតាមវិស័យនៃក្រសួងស្ថាប័នថ្នាក់ជាតិសម្រាប់ថវិកាមន្ទីរជំនាញរាជធានី-ខេត្ត ដំណើរការនៃការធ្វើសមាហរណកម្មតាមខ្សែទទឹងនិងការតម្រឹមតាមខ្សែបណ្តោយ គឺធ្វើឡើងក្នុងគោលដៅប្រើប្រាស់ធនធានដែលមានកម្រិត ដើម្បីសម្រេចឱ្យបានសមិទ្ធផលជាអតិបរមា សម្រាប់ជាគុណប្រយោជន៍នៃថ្នាក់ក្រោមជាតិ។ ប្រការនេះតម្រូវឱ្យមានការកែលម្អដំណើរការប្រឹក្សាយោបល់និងការសម្របសម្រួលរវាងក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងដំណាក់កាលនៃការធ្វើផែនការយុទ្ធសាស្ត្រថវិកា និងការគាំទ្រដល់ការកសាងសមត្ថភាពថ្នាក់ក្រោមជាតិ។

ដើម្បីពង្រឹងនូវវិន័យថវិកាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងកំណត់នូវពិដានថវិកាសម្រាប់ថ្នាក់ក្រោមជាតិដែលនឹងក្លាយជាមគ្គុទ្ទេសក៍សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានីខេត្ត។ផែនការយុទ្ធសាស្ត្រថវិការាជធានី-ខេត្ត និងធ្វើសមាហរណកម្មជាមួយនឹងគោលនយោបាយថ្នាក់រាជធានីខេត្តដើម្បីគាំទ្រដល់គោលនយោបាយ និងលទ្ធផលតាមវិស័យដូចមានបង្ហាញនៅក្នុងដ្យាក្រាមទី៥ខាងលើ។ ថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់ ឃុំ សង្កាត់នឹងរៀបចំផែនការអន្តរាគមន៍របស់ខ្លួនដើម្បីគាំទ្រដល់អាទិភាព គោលនយោបាយរដ្ឋបាលរាជធានីខេត្តដែលជាវិភាគទានទៅដល់ការសម្រេចបានអាទិភាពតាមវិស័យនិងអាទិភាពជាតិ។ ដោយសារផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលរាជធានីខេត្តត្រូវបានរៀបចំដោយផ្អែកលើអាទិភាពតាមវិស័យពីថ្នាក់ជាតិចុះមកផែនការយុទ្ធសាស្ត្រថវិកានេះក៏ត្រូវផ្តល់ភាពទន់ភ្លន់ឱ្យមានការដាក់បញ្ចូលនូវអាទិភាពនៅថ្នាក់មូលដ្ឋានដែលជាតម្រូវការ និងសំណូមពរ។

**ក. វដ្តថវិកាការធ្វើផែនការយុទ្ធសាស្ត្រថវិកា**

ដោយអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានបើកច្រកឱ្យរាជរដ្ឋាភិបាលអាចអនុវត្តសាលល្បងថវិកាកម្មវិធីដែលជាជំហ៊ានមួយនៅលើទិសដៅឆ្ពោះទៅរកប្រព័ន្ធថវិកាសមិទ្ធកម្ម និងវិមជ្ឈការដែលមានសមាសធាតុកែទម្រង់គន្លឹះដូចបានរៀបរាប់ក្នុងផ្នែកខាងដើមនៃជំពូកនេះ។ ក្នុងន័យនេះ ដើម្បីឲ្យប្រព័ន្ធថវិកាសមិទ្ធិផលត្រូវបានដាក់ឱ្យអនុវត្តដោយផ្អែកលើបទដ្ឋានគតិយុទ្ធច្បាស់លាស់ពេញលេញ និងគ្រប់ជ្រុងជ្រោយច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈបច្ចុប្បន្ននេះចាំបាច់ត្រូវធ្វើវិសោធនកម្ម។

**ខ.ដំណើរការរៀបចំថវិកាប្រចាំឆ្នាំ**

បច្ចុប្បន្ន ការគ្រោងថវិកាប្រចាំឆ្នាំជាទូទៅត្រូវបានរៀបចំឈរលើមូលដ្ឋានកំណើនប្រចាំឆ្នាំ ដើម្បីផ្តល់សេវាសាធារណៈពីមួយឆ្នាំទៅមួយឆ្នាំទៀតទោះបីថវិកាកម្មវិធីត្រូវបានអនុវត្តមួយរយៈហើយក៏ដោយ។ ការគ្រោងថវិកាត្រូវបានកែសម្រួលខ្លះៗទៅតាមអត្រានៃការតម្លើងប្រាក់បៀវត្សកំណើនសុទ្ធនៃចំនួនបុគ្គលិកការអនុវត្តថវិកាក្នុងឆ្នាំ និងការប្រែប្រួលថ្លៃដែលមិនបានរំពឹងទុកជាមុន។ ក្រសួងស្ថាប័ននីមួយៗអាចស្នើសុំថវិកាបន្ថែមស្របគ្នាទៅតាមផែនការយុទ្ធសាស្ត្រថវិកា និងក្នុងទំហំអត្រាកំណើនដែលបានកំណត់ជាពិដានសម្រាប់ក្រសួងស្ថាប័ន។ ក្រសួងស្ថាប័នត្រូវការពារសំណើរនេះជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្នុងកិច្ចប្រជុំពិភាក្សាគម្រោងថវិកាដែលបច្ចុប្បន្នផ្តោតជាសំខាន់លើធាតុចូល និងលទ្ធផលក្នុងឆ្នាំមួយចំនួន។

ថវិកាប្រចាំឆ្នាំឆ្លុះបញ្ចាំងអំពីការផ្សារភ្ជាប់រវាងគោលនយោបាយតាមវិស័យ ជាមួយនឹងក្របខ័ណ្ឌគោលនយោបាយម៉ាក្រសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ តាមរយៈការផ្សារភ្ជាប់រវាងក្របខណ្ឌថវិការយៈពេលមធ្យម និងផែនការយុទ្ធថវិកា ហើយដែលគោលនយោបាយតាមវិស័យ និងក្របខណ្ឌគោលនយោបាយ ម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈត្រូវបានរៀបចំដោយផ្អែកលើគោលនយោបាយជាតិ( យុទ្ធសាស្ត្រចតុកោណនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ )។

គោលដៅសម្រាប់ឆ្នាំ២០២៥ គឺការពិភាក្សាលើសំណើថវិកាទាំងថវិកាចរន្ត ទាំងថវិកាមូលធននឹងត្រូវផ្អែកជាសំខាន់លើសមិទ្ធផលនៃកម្មវិធីជាពិសេសលើសំណើរថវិកាថ្មីដែលនិងរួមចំណែកដល់ការសម្រេច គោលបំណងនៃកម្មវិធីលទ្ធផលក្នុងឆ្នាំលទ្ធផលចុងក្រោយ និងលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធី។

ការពិភាក្សាដេញដោលអំពីគម្រោងថវិកានៅតែផ្អែកលើគោលការណ៍កំណើនប្រចាំឆ្នាំ ប៉ុន្តែដើម្បីបង្កើនភាពបត់បែននៃថវិកាបានក្រសួងស្ថាប័នត្រូវខិតខំសន្សំសំចៃ ដើម្បីធ្វើការវិភាគថវិកាឡើងវិញសិន។

**គ.ការចរចារ និងការអនុម័តថវិកា**

ទោះបីជាដំណើរការរៀបចំគម្រោងថវិកាក្រសួងស្ថាប័ន និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ធ្វើឡើងតាមដំណើរការពីរផ្សេងគ្នាក្តីក៏ការរៀបចំថវិកាទាំងពីរនេះជួបប្រសព្វគ្នានៅកម្រិតរាជធានីខេត្ត។ ថវិកាមន្ទីរជំនាញរាជធានីខេត្តត្រូវបានរៀបចំដោយក្រសួងស្ថាប័នដោយផ្អែកលើផែនការនីយកម្មពីលើចុះក្រោមទៅជាផ្នែកមួយនៃថវិកាជាតិ។ ថវិការដ្ឋបាលថ្នាក់រាជធានី-ខេត្តត្រូវបានរៀបចំ និងដាក់ឱ្យក្រុមប្រឹក្សាទៅតាមអាទិភាពជាតិហើយត្រូវបានចរចារ និងយល់ព្រមដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួចអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិជាផ្នែកមួយនៃថវិកាជាតិ។ ថវិការដ្ឋបាលថ្នាក់រាជធានីខេត្តត្រូវបានរៀបចំ និងដាក់ឱ្យក្រុមប្រឹក្សារាជធានី ខេត្តពិនិត្យនិងអនុម័តហើយត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចរចានិងយល់ព្រមនិងបូកសរុបដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។ ដោយឡែកថវិកាសរុបសម្រាប់ ក្រុង ស្រុក និង ថវិកាសម្រាប់ឃុំ សង្កាត់ ត្រូវបានវិភាជក្នុងសមាមាត្រជាក់លាក់នៃចំណូលចរន្តថ្នាក់ជាតិឆ្នាំកំពុងអនុវត្ត។ទំហំនៃការវិភាជនេះត្រូវកំណត់ដោយផ្អែកតាមរូបមន្តជាក់លាក់មួយដែលជាអនុគមន៍នៃចំណែកស្មើៗគ្នា ទំហំប្រជាជន សន្ទស្សន៍នៃភាពក្រីក្រចំនួនក្រុមប្រឹក្សា និងចំនួនឃុំ សង្កាត់ (សម្រាប់ ក្រុង ស្រុក)

ឬចំនួនភូមិ (សម្រាប់ឃុំ សង្កាត់)។ រដ្ឋបាលរាជធានី ខេត្តផ្តល់នូវការគាំទ្របច្ចេកទេសដល់ការរៀបចំថវិកាក្រុង ស្រុក។បន្ទាប់ពីក្រុមប្រឹក្សាធ្វើការត្រួតពិនិត្យនិងអនុម័តថវិកាក្រុងស្រុករួចមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការបូកសរុប ថវិកានេះនៅតាមខេត្តនីមួយៗរួចបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋបាលឃុំសង្កាត់នីមួយៗរៀបចំថវិកាដោយខ្លួនឯងរួចដាក់ឱ្យក្រុមប្រឹក្សាខ្លួនពិនិត្យនិងអនុម័តបន្ទាប់មកបញ្ជូនទៅរាជធានី ខេត្ត ដើម្បីត្រួតពិនិត្យ និងផ្តល់អនុលោមភាពថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុម័តជាកញ្ចប់ដោយស្ថាប័ននីតិប្បញ្ញត្តិ ជាផ្នែកមួយនៃថវិកាជាតិ។ មន្ទីរជំនាញរាជធានីខេត្ត មិនមានពាក់ព័ន្ធនៅក្នុងដំណើរការរៀបចំគម្រោងថវិកានេះទេ។ ទោះបីជាមានដំណើរការរៀបចំគម្រោងថវិកាការចរចារថវិកា និងការអនុម័តថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិច្បាស់លាស់ បែបនេះក្តីក៏ថវិការដ្ឋបាលថ្នាក់ក្រោមជាតិនៅមានបញ្ហាផ្នែកគុណភាព ភាពគ្រប់ជ្រុងជ្រោយ និងភាពមិនច្បាស់លាស់ នៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។

គោលបំណងនៅឆ្នាំ២០២៥ គឺធ្វើឱ្យថវិការដ្ឋបាលថ្នាក់ក្រោមជាតិមានភាពគ្រប់ជ្រុងជ្រោយដោយពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។ ថវិកាចរន្ត និងថវិកាមូលធននឹងត្រូវធ្វើសមាហរណកម្ម។ ការចរចារថវិការដ្ឋបាលថ្នាក់រាជធានី-ខេត្តនឹងតម្រង់ទិសឆ្ពោះទៅរកការផ្តោតលើលទ្ធផលក្នុងឆ្នាំនៃកម្មវិធី។ ដោយសារប្លង់គណនីតម្រូវឱ្យមានការឯកភាពគ្នាហើយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនឹងត្រូវដាក់ពង្រាយទៅដល់រដ្ឋបាលរាជធានីខេត្ត ដូចនេះចំណាត់ថ្នាក់ថវិកានឹងត្រូវប្រើដូចគ្នានឹងថ្នាក់ជាតិដែរ។ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនឹងមានតែមួយ ដែលរួមមានថវិកាថ្នាក់ជាតិ និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។ ថវិការដ្ឋបាលរាជធានីខេត្តនឹងឆ្លុះបញ្ចាំងជាសរុបតាមខេត្តនីមួយៗដោយចែកជាថវិកាចរន្ត និងថវិកាមូលធនជាឧបសម្ព័ន្ធនៃច្បាប់។ ដោយឡែក ថវិការបស់រដ្ឋបាលក្រុង ស្រុក និង ឃុំ សង្កាត់ នឹងត្រូវឆ្លុះបញ្ចាំងជាទំហំសរុបដែលជាលទ្ធផលនៃការវិភាជលទ្ធផលតាមរដ្ឋបាលនីមួយៗដោយផ្អែកលើរូបមន្តបែងចែកជាក់លាក់ និងផ្អែកលើសមិទ្ធកម្ម។ នៅពេលខាងមុខ នៅពេលប្រព័ន្ធគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែត្រូវបានកែលម្អ គោលការណ៍នយោបាយការរៀបចំ និងអនុម័តថវិកានឹងត្រូវពិនិត្យឡើងវិញស្របតាមឧត្តមានុវត្តជាអន្តរជាតិ។ ជារួមការកែទម្រង់ការរៀបចំថវិកាការចរចារថវិកា ការយល់ព្រមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុព្រមទាំងការដាក់ជូនគណៈរដ្ឋមន្ត្រី និងស្ថាប័ននីតិប្បញ្ញត្តិពិនិត្យ និងអនុម័តគឺត្រូវធ្វើឱ្យស៊ីចង្វាក់គ្នានៅក្រោមគោលការណ៍នៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ជាតិ។

**ឃ.ប្រព័ន្ធរបាយការណ៍ តាមដាននិងការវាយតម្លៃថវិកា**

ប្រព័ន្ធគ្រប់គ្រងដោយផ្អែកលើសមិទ្ធកម្មល្អៗកន្លងតម្រូវឱ្យមានការតាមដាននិងវាយតម្លៃជាទៀងទាត់។ ប្រព័ន្ធនេះផ្តល់ជាយន្តការទទួលព័ត៌មានត្រឡប់មកសម្រាប់ធ្វើការសម្រេចចិត្តនៅគ្រប់កម្រិតនិងស្វែងយល់អំពីវឌ្ឍនភាពប្រសិទ្ធភាពនិងសក្តិសិទ្ធភាពនៃកម្មវិធីនីមួយៗហើយសំខាន់ជាងនេះគឺការដាក់វិធានការកែតម្រូវទាន់ពេលវេលានៅពេលដែលកម្មវិធីមិនមានវឌ្ឍភាពល្អ ឬមានវឌ្ឍនភាពលឿនជ្រុលទៅមុខ។ មូលហេតុនៃវឌ្ឍនភាពទាបពេក(ឬខ្ពស់ជ្រុល)ដោយសារការរៀបចំកម្មវិធីមិនបានល្អគោលដៅមិនត្រឹមត្រូវមិនសមស្រប ការគ្រប់គ្រងកម្មវិធីមិនបានល្អ និងធនធានមិនមានគ្រប់គ្រាន់។

ប្រការនីមួយៗខាងលើទាមទារនូវការឆ្លើយតបខុសៗគ្នាពីអ្នកគ្រប់គ្រងដែលអាចពាក់ព័ន្ធឬមិនពាក់ព័ន្ធនឹងថវិកា។ បច្ចុប្បន្នប្រព័ន្ធតាមដានរបស់ក្រសួងស្ថាប័ន និងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយទេ។ សម្រាប់ការវាយតម្លៃវិញ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មសមិទ្ធកម្មប៉ុន្តែនៅមានកម្រិត ហើយផ្តោតលើការធ្វើសវនកម្មហិរញ្ញវត្ថុជាចម្បង។ ទន្ទឹមនឹងនេះនីតិវិធីជាប្រព័ន្ធសម្រាប់វាយតម្លៃកម្មវិធីក៏មិនទាន់មាននៅឡើយដែរ។

ចំពោះសវនកម្មផ្ទៃក្នុងនៅតាមក្រសួងស្ថាប័នវិញនាពេលបច្ចុប្បន្ននេះ កំពុងបំពេញតួនាទីសវនកម្មសមិទ្ធកម្មតិចតួច។ តួនាទីរបស់សវនកម្មផ្ទៃក្នុងត្រូវពង្រឹងនិងតម្រង់ទិសឆ្ពោះទៅរកការវាយតម្លៃសមិទ្ធកម្មរបស់អង្គភាពថវិកា និងការផ្តល់សេវាគោលបំណងសម្រាប់ឆ្នាំ២០២៥ គឺការតាមដាន និងវាយតម្លៃកម្មវិធីនឹងធ្វើឡើងជាប្រព័ន្ធស្របទៅតាមឧត្តមានុវត្តជាអន្តរជាតិ។ ប្រការនេះទាមទារឱ្យមានការរៀបចំលិខិតបទដ្ឋាន និងគោលការណ៍ណែនាំពាក់ព័ន្ធនានាបង្កើនការយល់ដឹង និងការកសាងសមត្ថភាពផ្នែកសវនកម្មសមិទ្ធកម្ម។ ជាគោល-ការណ៍ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមដានជាទៀងទាត់នៅពាក់កណ្តាលឆ្នាំ និងប្រចាំឆ្នាំនៃការអនុវត្ត ថវិកាកម្មវិធី ដើម្បីពិនិត្យអំពីវឌ្ឍនភាពនៃការសម្រេចបាននូវគោលបំណងនិងលទ្ធផលដែលបានគ្រោងទុក។ ក្រសួងស្ថាប័ននីមួយៗនឹងត្រូវតាមដានជាប្រចាំការអនុវត្តកម្មវិធីរបស់ខ្លួនផងដែរ ដើម្បីពិនិត្យមើលការសម្រេចបាននូវគោលបំណងនិងលទ្ធផលដែលបានគ្រោងទុក។ ការតាមដានដែលធ្វើឡើងដោយក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន នឹងក្លាយជាមូលដ្ឋានឈានទៅកែសម្រួលកម្មវិធី។ ក្រសួង-ស្ថាប័ន អាចធ្វើការវាយតម្លៃ ស៊ីជម្រៅតាមការចាំបាច់ ដើម្បីពិនិត្យអំពីប្រសិទ្ធភាពនៃកម្មវិធីនីមួយៗ។

កម្មវិធីទាំងអស់គួរតែជាកម្មវត្ថុនៃការតាមដានជាទៀងទាត់ប៉ុន្តែការវាយតម្លៃកម្មវិធីនឹងធ្វើឡើងតែលើកម្មវិធីមួយចំនួននិងតាមតម្រូវការជាក់ស្តែង។ការវាយតម្លៃកម្មវិធីត្រូវការជំនាញពាក់ព័ន្ធច្រើន ទាំងផ្នែកហិរញ្ញវត្ថុ ទាំងផ្នែកជំនាញបច្ចេកទេសច្បាស់លាស់នៅក្នុងវិស័យនោះ។ ដោយសារការងារនេះត្រូវចំណាយច្រើន ការវាយតម្លៃគ្រប់ជ្រុងជ្រោយគួរតែផ្តោតលើកម្មវិធីណាដែលមានទំហំថវិកាធំហានិភ័យខ្ពស់ ឬមានសារៈសំខាន់ខ្ពស់ផ្នែកនយោបាយ ឬមានបញ្ហាផ្នែកសមិទ្ធកម្ម។ បច្ចុប្បន្ននេះការវាយតម្លៃកម្មវិធីបែបលក្ខណៈទូលាយត្រូវបានធ្វើឡើងម្តងម្កាល ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍ។

នៅត្រឹមឆ្នាំ២០២៥ នឹងមានក្របខ័ណ្ឌតាមដាន និងវាយតម្លៃកម្មវិធីដែលគ្រប់ជ្រុងជ្រោយ និងច្បាស់លាស់ដោយរួមមានសមាសធាតុសំខាន់ៗដូចខាងក្រោម៖

- ការពិនិត្យតាមដានការអនុវត្តពាក់កណ្តាលឆ្នាំ និងប្រចាំឆ្នាំការតាមដានស៊ីជម្រៅអំពីប្រសិទ្ធភាព នៃការរៀបចំ និងការអនុវត្តកម្មវិធី។
- ការវាយតម្លៃកម្មវិធីដោយគ្រប់ជ្រុងជ្រោយតាមការចាំបាច់ និងការវាយតម្លៃក្រោយការអនុវត្តតាមការជ្រើសរើស។

ក្រសួង-ស្ថាប័ននីមួយៗត្រូវតាមដានជាប្រចាំ និងអាចត្រួតពិនិត្យឡើងវិញស៊ីជម្រៅជាយថាហេតុ ដើម្បីអាចចាត់វិធានការកែតម្រូវទាន់ពេល និងមានប្រសិទ្ធភាពចំពោះកម្មវិធីណាដែលអនុវត្តចាកខុសផ្លូវ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមដានការអនុវត្តកម្មវិធីនិងអាចពិនិត្យឡើងវិញជាលក្ខណៈសាមញ្ញនូវសមិទ្ធកម្ម កម្មវិធី ដោយផ្អែកលើទិន្នន័យអនុវត្តថវិកា និងសមិទ្ធកម្ម ដើម្បីប្រើប្រាស់ជាការផ្តល់ព័ត៌មានសម្រាប់ជួយដល់ការវិភាជថវិកា ប៉ុន្តែមិនមែនកត្តាកំណត់ក្នុងការវិភាជនោះទេ។ កម្មវិធីមួយចំនួននឹងជាកម្មវត្ថុនៃការវាយតម្លៃគ្រប់ជ្រុងជ្រោយតាមការចាំបាច់ ដើម្បីស្វែងយល់ និងរកមូលហេតុនៃភាពឃ្លាតពីគ្នារវាងគម្រោងថវិកា និងលទ្ធផលទទួលបានដោយធ្វើការពិនិត្យមើលទាំងការវាស់វែងចំណាយ និងការវាស់វែងសមិទ្ធកម្ម។ ការវាយតម្លៃក្រោយការអនុវត្តកម្មវិធីដើម្បីប្រមូលផ្តុំបទពិសោធន៍និងមេរៀននឹងត្រូវធ្វើតែលើកម្មវិធីមួយចំនួនតាមការជ្រើសរើស។

អាជ្ញាធរសវនកម្មជាតិមានភារកិច្ចធ្វើការពិនិត្យឡើងវិញដោយឯករាជ្យលើសមិទ្ធកម្មនៃកម្មវិធី ទៅតាមអាណត្តិការងាររបស់ខ្លួន។ ការងារទាំងនេះរួមមានការពិនិត្យសុពលភាពចំណាយប្រសិទ្ធភាពនៃកម្មវិធី ការធ្វើសវិកម្មទៅលើសូចនាករសមិទ្ធកម្មមិនមែនហិរញ្ញវត្ថុក៏ដូចជាពិនិត្យឡើងវិញនូវការរៀបចំ និងការគ្រប់គ្រងកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ។[២]

## ផ្នែកទី២

## លទ្ធផលនិងការវិភាគលើការអនុវត្ត

### ២.៥. លទ្ធផលនៃការកែទម្រង់

#### ២.៥.១. លទ្ធផលកំណែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥

ឆ្លងកាត់តាមបទពិសោធន៍នៃការអនុវត្តតាមទិសដៅនៃទស្សនាទានស្តីពីយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា២០១៣-២០២០កន្លងមក និងផ្អែកតាមការសិក្សាវាយតម្លៃរបស់គណៈកម្មាធិកាដឹកនាំការងារ

[២] យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥

កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអ្នកជំនាញពាក់ព័ន្ធស្ដីពីវឌ្ឍភាពនៃការអនុវត្តថវិកាកម្មវិធី បានបង្ហាញថាការកំណត់គោលដៅឆ្នាំ២០២០ ក្នុងការចាប់ផ្ដើមអនុវត្តប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្មគឺមានមហិច្ឆតាខ្ពស់ពេក។ ក្នុងន័យនេះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូនព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិកាដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានចាត់តាំងក្រុមការងារមួយឱ្យរៀបចំឯកសារយុទ្ធសាស្ត្រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយសម្រាប់ជាមូលដ្ឋាន នៃការកែទម្រង់ប្រព័ន្ធថវិកាក្នុងរយៈពេលវែងគឺ "យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥" ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិនិងតថភាពជាក់ស្តែងនៃកម្ពុជា។យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ដែលត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនាថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ ត្រូវបានរៀបចំឡើងដោយក្រុមការងាររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលបានឆ្លងកាត់ការសិក្សា និងដកស្រង់បទពិសោធន៍ពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ និងពីបណ្ដាប្រទេសមួយចំនួន ដូចជា ប្រទេសបារាំង ស៊ុយអែត ថៃ និងម៉ាឡេស៊ី ជាពិសេសផ្អែកលើបទពិសោធន៍នៃការអនុវត្តការងារជាក់ស្តែងរយៈពេលជាច្រើនឆ្នាំរបស់កម្ពុជាផ្ទាល់ ក៏ដូចជាការចូលរួមចែករំលែកបទពិសោធន៍ពីអ្នកជំនាញជាច្រើននាក់ព្រមទាំងបានឆ្លងកាត់ការពិភាក្សាជាច្រើនលើក ច្រើនសារនៅផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍសំខាន់ៗ។

ជាលទ្ធផលយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ បានផ្ដល់ជាក្របខ័ណ្ឌ ទស្សនាទានសម្រាប់តម្រង់ទិសការរៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ជាតិ ដូចខាងក្រោម៖

ទី១ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផ្អែកលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យមតែមួយ។

ទី២ ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំមានតែមួយដែលរួមមានថវិកាថ្នាក់ជាតិ និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។

ទី៣ រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើឲ្យមានការផ្សារភ្ជាប់ទំនាក់ទំនងគ្នា បំពេញឲ្យគ្នា និងប្រទាក់ក្រឡាគ្នាទៅវិញទៅមកតាមរយៈការធ្វើការតម្រឹមផែនការនីយកម្ម ដើម្បីសម្រេចគោលបំណងរួមនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ។

ទី៤ ការផ្ដល់អំណាច និងការទទួលខុសត្រូវដល់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានប្រមូលផ្តុំមុខងារត្រួតពិនិត្យហិរញ្ញវត្ថុ និងកិច្ចលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ជាតិ។

ទី៥ ការធ្វើស្ថាប័ននីយកម្មជាបណ្ដើរៗនៃរបបរបាយការណ៍នៅថ្នាក់ជាតិ និងបង្កើនសមត្ថភាពថ្នាក់ជាតិក្នុងការធ្វើរបាយការណ៍។

### ២.៥.២. លទ្ធផលកំណែទម្រង់ថវិកាថ្នាក់ជាតិ

គោលដៅនៃយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ គឺពង្រឹងការអនុវត្តថវិកាកម្មវិធីឱ្យបានពេញលេញនិងកសាងមូលដ្ឋានសម្រាប់ការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្មដើម្បីធានាឱ្យបាននូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ជាពិសេសគោលបំណងគោលនយោបាយរដ្ឋបាលថ្នាក់ជាតិត្រូវតម្រឹមជាមួយនឹងគោល

បំណង ឬអាទិភាពគោលនយោបាយជាតិ។ ក្នុងគោលដៅនេះ ការធ្វើសមាហរណកម្មផែនការនីយកម្មមានភាពចាំបាច់ ដើម្បីឱ្យផែនការយុទ្ធសាស្ត្ររដ្ឋបាលថ្នាក់ជាតិមានការផ្សារភ្ជាប់ទំនាក់ទំនងគ្នាបំពេញឱ្យគ្នា និងប្រទាក់ក្រឡាគ្នាទៅវិញទៅមក និងតម្រឹមទៅនឹងផែនការយុទ្ធសាស្ត្រថ្នាក់ក្រោមជាតិ។ ការរៀបចំផែនការថវិកាប្រចាំឆ្នាំចាំបាច់ត្រូវធានាឱ្យមានសង្គតិភាពជាមួយនឹងផែនការយុទ្ធសាស្ត្រថវិកា និងត្រូវឱ្យមានការចូលរួមកាន់តែទូលំទូលាយពីភាគីពាក់ព័ន្ធ។ ទន្ទឹមនឹងនេះការវិភាជនិងការអនុវត្តថវិកានឹងត្រូវបានបង្កើនប្រសិទ្ធភាពថែមទៀតតាមរយៈការកែលម្អ និងការធ្វើសាមញ្ញកម្មនីតិវិធីចំណាយជាពិសេសការផ្តល់ឆន្ទានុសិទ្ធិ និងគណនេយ្យភាពដល់រដ្ឋបាលថ្នាក់ជាតិ។ការរៀបចំរបាយការណ៍នឹងត្រូវធ្វើឱ្យបានទាន់ពេលវេលា ហើយការបង្កើនសមត្ថភាពរដ្ឋបាលថ្នាក់ជាតិក្នុងការធ្វើរបាយការណ៍តាមកម្មវិធីនឹងត្រូវពង្រឹងបន្ថែមទៀត។

កំណែទម្រង់នេះ ដាក់ចេញនូវសកម្មភាពកែទម្រង់តាមអភិក្រមដែលមានលក្ខណៈសាមញ្ញទន់ភ្លន់តម្លាភាពនិងគណនេយ្យភាពដោយផ្តោតលើសមាសធាតុគន្លឹះនៃវដ្តថវិកា និងសមាសធាតុដែលជារចនាសម្ព័ន្ធទ្រទ្រង់រួមមានក្របខ័ណ្ឌគតិយុត្តការកសាងនិងអភិវឌ្ឍសមត្ថភាព និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់ពីឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២៥។

## ២.៦. វិភាគ

### ២.៦.១. ចំណុចខ្លាំង

ដោយផ្អែកទៅតាមការវាយតម្លៃពាក់កណ្តាលឆ្នាំ២០២០ សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ានស្មានថានឹងមានកំណើនសេដ្ឋកិច្ចអវិជ្ជមាន១,៩%គឺទាបជាងការព្យាករណ៍នៅពេលរៀបច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ដោយសារបញ្ហានៃការរីករាលដាលនៃជម្ងឺកូវីដ-១៩។ ក្នុងបរិការណ៍នេះ កម្ពុជាអាចជួបហានិភ័យពីកត្តាខាងក្រៅប្រទេស និងបញ្ហាប្រឈមមួយចំនួននៅក្នុងប្រទេស ដែលតម្រូវឲ្យរដ្ឋាភិបាលដាក់ចេញវិធានការមុតស្រួចនិងទាន់ពេលវេលាដើម្បីបញ្ចៀស និងបន្ធូរបន្ថយសម្ពាធហានិភ័យ និងបញ្ហាប្រឈមនានាដែលអាចកើតឡើងជាយថាហេតុ តាមរយៈការដាក់ចេញ និងអនុវត្តវិធានការគោលនយោបាយ ដែលឆ្លើយតបទាំងក្នុងផ្នែកម៉ាក្រូសេដ្ឋកិច្ច និងទាំងក្នុងផ្នែកហិរញ្ញវត្ថុសាធារណៈ។

សំខាន់ជាងនេះទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងបន្តតាមដាន និងវាយតម្លៃជាប់ជាប្រចាំប្រកបដោយការយកចិត្តទុកដាក់ខ្ពស់លើស្ថានភាពវិវត្តន៍នៃការរីករាលដាលនៃជម្ងឺកូវីដ-១៩ ដើម្បីត្រៀមបើកឡើងវិញជាបណ្តើរៗនូវសកម្មភាពអាជីវកម្ម/ធុរកិច្ចដែលរាជរដ្ឋាភិបាលបានណែនាំឱ្យផ្អាកដំណើរការមួយរយៈពេលកន្លងមកក៏ដូចជាត្រៀមលក្ខណៈក្នុងការដាក់ចេញវិធានការអន្តរាគមន៍ឆ្លើយតបឱ្យទាន់ពេលវេលាក្នុងករណីរលកទី២នៃការរីករាលដាលនៃជម្ងឺកូវីដ-១៩ ផ្ទុះឡើង។

ជាមួយគ្នានេះ កំណែទម្រង់រដ្ឋបាលថ្នាក់ជាតិលើវិស័យថវិកាបានឆ្លុះបញ្ចាំងអំពីលទ្ធផល និងប្រសិទ្ធិភាពនៃការកៀរគរចំណូលតាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ជាពិសេសការលើកកម្ពស់វប្បធម៌បង់ពន្ធ ការបង្ក្រាបអំពើរត់ពន្ធនិងការគេចវេសពន្ធគ្រប់រូបភាពឱ្យដល់ឬសគល់ និងការកែលម្អអភិបាលកិច្ចក្នុងការប្រមូលចំណូល ព្រមទាំង

ប្រសិទ្ធភាពនៃប្រតិបត្តិការចំណាយតាមរយៈការតម្រង់ការចាយឱ្យចំមុខ និងមិនខ្ជះខ្ជាយ ដែលធ្វើឱ្យរដ្ឋាភិបាលមានលទ្ធភាពឆ្លើយតបបានកាន់តែមានប្រសិទ្ធភាពទៅនឹងបណ្តាតម្រូវការជាអាទិភាពនានាជាពិសេសការអនុវត្តក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២០ ដែលត្រូវបានរៀបចំឡើងស្របតាមអាទិភាពគោលនយោបាយ។

ដូចនេះកំណែទម្រង់រដ្ឋបាលថ្នាក់ជាតិលើវិស័យថវិកាពិតជាដើរតួនាទីជាឧបករណ៍នៃគោលនយោបាយរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពក្នុងការរក្សាលំនឹងសេដ្ឋកិច្ច និងជីវភាពរបស់ប្រជាជនទប់ទល់នឹងផលប៉ះពាល់ពីជម្ងឺកូវីដ-១៩ដ៏កាចសាហាវព្រមទាំងបម្រើដល់ការស្តារសេដ្ឋកិច្ច និងជម្រុញកំណើនជាបណ្តើរៗឡើងវិញហើយកំណែទម្រង់នេះត្រូវបានរៀបចំឡើងដោយឈរលើគោលការណ៍បច្ចេកទេសសំខាន់ៗដូចជា៖

-ការធានាចីរភាព និងសមិទ្ធកម្មនៃចំណូល

-ការកំណត់លំដាប់អាទិភាព

-ការកំណត់តម្លៃជាក់ស្តែងនៃកម្មវិធី/សកម្មភាព

-ការផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្ត

-ការផ្សារភ្ជាប់រវាងការប្រមូលចំណូល និងភាពវិភាជថវិកា

-ការរក្សាតុល្យភាព និងចីរភាពថវិកា។

### ២.៦.២. ចំណុចខ្វះខាត

បញ្ហាប្រឈមនានាដែលលើកឡើងខាងលើមានបង្ហាញពីភាពខ្វះខាតមួយចំនួនដែលបង្កជាផលវិជ្ជមានដល់ដំណើរការអនុវត្តកិច្ចការងារកំណែទម្រង់វិស័យថវិកាមានចំណុចដូចខាងក្រោមៈ

**ការបណ្តុះបណ្តាលៈ** ការបណ្តុះបណ្តាលជាផ្នែកមួយដ៏សំខាន់បំផុតក្នុងការកសាងមូលដ្ឋានគ្រឹះ ធនធានមនុស្សខ្លាំង។ ការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យថវិកា ពុំទាន់មានភាពទូលំទូលាយ បច្ចុប្បន្នការបណ្តុះបណ្តាលធនធានមនុស្សធ្វើឡើងតាមរយៈរូបភាពពីរគឺក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនៅក្នុងអង្គភាពផ្ទាល់ដែលនេះជាចំនួនតិចតួចក្នុងការបណ្តុះបណ្តាលពង្រឹងសមត្ថភាព ធនធានមនុស្សខ្លាំង។

**ទំនាក់ទំនងការងារៈ**ពីស្ថាប័នមួយទៅស្ថាប័នមួយពុំសូវមានភាពស៊ីសង្វាក់គ្នា និងពុំទាន់មានលក្ខណៈជាប្រព័ន្ធនៅឡើយជាហេតុនាំឱ្យការងារមួយចំនួនមានភាពយឺតយ៉ាវ។

**សមត្ថភាពធនធានមនុស្សៈ** សមត្ថភាពធនធានមនុស្សមានការកើនឡើងក៏ពិតមែន ប៉ុន្តែពុំទាន់ឆ្លើយតបនឹងតម្រូវការរបស់រាជរដ្ឋាភិបាល និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋនៅឡើយ ដែលជាហេតុធ្វើឲ្យមានគម្លាតរវាងគោលនយោបាយ និងការអនុវត្តជាក់ស្តែង។

# សេចក្តីសន្និដ្ឋាន

ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ យើងឃើញថាប្រព័ន្ធថវិកានៅកម្ពុជាមានភាពអាក់រអួល ក៏ដូចជាមិនសមស្របទៅនឹងគោលដៅថវិការដែលបានគ្រោងទុករបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយយើងបានដឹងយ៉ាងច្បាស់ពីមូលហេតុចម្បងដែលធ្វើឱ្យបញ្ហានេះកើតមានឡើង នោះគឺការរាតត្បាតយ៉ាងធ្ងន់ធ្ងរនៃជម្ងឺកូវីដ-១៩ ដែលធ្វើឲ្យចំណូល-ចំណាយថវិកាជាតិមិនមានភាពសមាមាត្រនឹងគ្នាទាំងថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ហេតុដូច្នេះទើបរាជរដ្ឋាភិបាលក៏ដូចជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំនូវកំណែទម្រង់ប្រព័ន្ធថវិកាថ្នាក់ជាតិ ដើម្បីឱ្យប្រព័ន្ធថវិកាប្រព្រឹត្តទៅដោយមានសមិទ្ធផលមួយជាទីគាប់ចិត្ត ទោះស្ថិតនៅក្នុងស្ថានភាពនេះក៏ដោយ។ ក្នុងនោះដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់នូវវិធានការរិចារណកម្មថវិកាថ្នាក់ជាតិមួយចំនួនលើមូលដ្ឋានឥណទានថវិកា៥០%ចំណាយមុខសញ្ញាចំណាយមួយចំនួនដែរមិនចាំបាច់ ឬមិនចាំបាច់ខ្លាំង និងមិនសូវប៉ះពាល់ និងមិនសូវប៉ះពាល់សកម្មភាពការងាររបស់ក្រសួង-ស្ថាប័ន។ លើមូលដ្ឋាននេះ ក្រសួងស្ថាប័ន និងគ្រឹះស្ថានសាធារណៈរដ្ឋបាលពាក់ព័ន្ធចាំបាច់ត្រូវតែតម្រូវទំហំឥណទានសរុប រួមទាំងតារាង

ឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានរបស់ខ្លួនទៅតាមទំហំនៃមុខសញ្ញាចំណាយទាំងអស់ដែលបានកាត់សន្សំព្យួរខាងលើ និងទៅតាមកម្មវិធី និងចង្កោមសកម្មភាពពាក់ព័ន្ធ។

ការធ្វើកំណែទម្រង់នេះ បានពង្រឹងប្រសិទ្ធភាពចំណាយដែលបានដាក់ចេញខាងលើត្រូវបានគិតគូររៀបចំឡើងក្នុងក្របខណ្ឌនៃការធានាប្រក្រតីភាពនៃស្ថាប័នរដ្ឋ និងរក្សាលំនឹងជីវភាពប្រជាជន ទន្ទឹមនឹងការសន្សំធនធានថវិកាដើម្បីបង្វែរទៅបំពេញឱ្យសេដ្ឋកិច្ចត្រូវការចាំបាច់ និងបន្ទាន់របស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងការរាតត្បាតនៃជំងឺកូវីដ១៩ ពិសេសក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់នៅទីតាំងភូមិសាស្ត្រមួយចំនួន ដើម្បីបង្កើនសុវត្ថិភាពនិងដោះស្រាយជីវភាពជូនប្រជាពលរដ្ឋគ្រប់រូបជាពិសេសគ្រួសារក្រីក្រ និងជនងាយរងគ្រោះ។ ព្រមទាំងបានពង្រឹងប្រសិទ្ធភាពប្រតិបត្តិការចំណាយទាំងការលើកកម្ពស់តម្លៃលុយជាប្រភេទបរិមាណ និងទាំងប្រសិទ្ធិភាពបច្ចេកទេស។ ចំពោះការធ្វើវិចារណកម្មក៏បានទប់ស្កាត់ចំណាយដែលមិនចាំបាច់ឬដែលមិនមានផលចំណេញ ឬមិនមានផលប្រយោជន៍ច្បាស់លាស់សម្រាប់ក្រសួង-ស្ថាប័នសម្រេចគោលដៅបេសកកម្មការងាររបស់ខ្លួន ហើយបានរឹតបណ្តឹងចំណាយនៅតាមក្រសួងស្ថាប័ននីមួយៗ ដែលមិនមានផលដល់ការជំរុញការប្រើប្រាស់ក្នុងស្រុក។ ចំពោះផ្អាកការទិញសម្ភារឧបករណ៍មិនបន្ទាន់ និងដែលមានចរិកជាការនាំចូល ព្រមទាំងផ្អាកការផ្តល់គោលការណ៍ជួសជុលថ្មីៗ លើកលែងតែការជួសជុលអគារដែលមានស្រាប់ក៏បានធ្វើឲ្យរដ្ឋាភិបាលរក្សាការចំណាយដែលពុំសូវចាំបាច់មួយផ្នែកផងដែរ។ កំណែទម្រង់នេះក៏បានសម្រួលការអនុវត្តចំណាយឱ្យបានលឿន ជាពិសេសចំណាយការការពារ និងប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ដើម្បីទ្រទ្រង់សកម្មភាពសេដ្ឋកិច្ចនិងដើម្បីឆ្លើយតបឲ្យបានសមស្របទៅនឹងសភាពការណ៍វិវត្តន៍ជាក់ស្តែងឲ្យបានទាន់ពេលវេលា ។

បន្ទាប់ពីត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅឆ្នាំ២០០៤ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាមានវឌ្ឍនភាពយឺតក្នុងដំណើរព្យាសកម្មរយៈពេលពីរឬបីឆ្នាំដំបូងដោយសារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវការពេលវេលាក្នុងការស្រូបយកទស្សនៈនិងចំណេះដឹងថ្មីៗ ត្រូវការការសិក្សាពីប្រព័ន្ធថ្មីស្របទៅតាមដំណើរវិវត្តន៍ ឧត្តមានុវត្តអន្តរជាតិ ដកស្រង់បទពិសោធជាក់ស្តែងពីការអនុវត្តខ្លួនឯងផ្ទាល់និងពីប្រទេសនានាដែលបោះជំហានមុនកម្ពុជានិងថ្លឹងថ្លែងឱ្យត្រូវនឹងបរិការណ៍នៃដំណាក់កាលអភិវឌ្ឍន៍ ព្រមទាំងកំណត់ចក្ខុវិស័យឱ្យកាន់តែច្បាស់លាស់។ បន្ទាប់មកការកែទម្រង់បានបោះជំហានទៅមុខកាន់តែលឿនឡើង ជាពិសេសក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះដោយសារបុរេលក្ខខណ្ឌនានាសម្រាប់ការអនុវត្តកម្មវិធី ដែលមាសធាតុស្នូលនៃជំហានទី៣ត្រូវបានត្រៀមរៀបចំរួចរាល់ជាសារវន្តនិងកំពុងមានវឌ្ឍនភាពក្នុងការធ្វើស្ថាប័ននីយកម្ម។

នៅក្រោមចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា ដោយប្រែក្លាយទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០និងប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអាចចាត់ទុកជាកត្តាកំណត់មួយហើយការកែទម្រង់ប្រព័ន្ធថវិកាគឺជាឧបករណ៍គន្លឹះ ដើម្បីអាចសម្រេចបាននូវចក្ខុវិស័យនោះ។ ក្នុងន័យនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនឹងនៅតែបន្តជាការដ្ឋានកែមួយដ៏មានសារៈសំខាន់និងមុតស្រួច ក្នុងការឈានឆ្ពោះទៅសម្រេចជំហានទី៤នៅឆ្នាំ២០២៥។

ទោះជាយ៉ាងនេះក្តីទៅមុខទៀត ការកែទម្រង់ប្រព័ន្ធថវិកាអាចនឹងជួបបញ្ហាប្រឈមចម្បងៗមួយចំនួន គឺ -របៀបវារៈនៃការកែទម្រង់ត្រូវបានកំណត់ដោយសុទិដ្ឋិនិយមពេកនិងមិនប្រាកដនិយម ហើយការយល់អំពី ១) គុណតម្លៃនៃគោលបំណង និងមាគ៌ាឆ្ពោះទៅសម្រេចគោលដៅនៃតួអង្គពាក់ព័ន្ធនៅមានកម្រិត ២)- ជំហានមិនសូវ ស៊ីចង្វាក់ល្អ និងក្នុងល្បឿនខុសគ្នានៃការកែទម្រង់ប្រព័ន្ធថវិកាជាតិ ជាមួយនឹងការកែទម្រង់ធំៗ ដែលមានការពាក់ព័ន្ធនិងប្រទាក់ក្រឡាផ្សេងទៀត ៣- ការកសាងធនធានមនុស្សនិងសមត្ថភាពស្ថាប័នមិនទាន់មានវឌ្ឍនភាពសមាមាត្រទៅនឹងកិច្ចការកែទម្រង់ដែលកំពុងពេញល្បឿនដោយសារកិច្ចការនេះត្រូវការពេលវេលាយូរធនធានច្រើន និងឆន្ទៈរួមនៃតួអង្គពាក់ព័ន្ធជាពិសេសថ្នាក់ដឹកនាំគ្រប់កម្រិតនៃក្រសួង-ស្ថាប័ននិង ៤- ដំណើរការកែទម្រង់មានលក្ខណៈ ជីវភាពដោយសារឧត្តមានុវត្តអន្តរជាតិមានការវិវត្តទៅក្នុងបរិការណ៍សាកលលោកដែលមានការប្រែប្រួលជាប្រចាំ។

ជារួមយុទ្ធសាស្ត្រនេះបានដាក់ចេញគោលដៅដែលនៅតែមានមហិច្ឆតាខ្ពស់ និងបានកំណត់ឃើញនូវហានិភ័យសំខាន់ៗមួយចំនួនដែលអាចជួបប្រទះនៅក្នុងពេលអនុវត្ត។ ទោះយ៉ាងនេះក្តី កម្ពុជាចាំបាច់ត្រូវពុះពារសម្រេចឱ្យបាននូវគោលដៅទាំងនោះជាសារវន្ត ដើម្បីឆ្លើយតបទៅនឹងសភាពការណ៍កម្ពុជាដែលកំពុងឈានដល់ដំណាក់កាលថ្មីនៃការអភិវឌ្ឍន៍ដូចជា និន្នាការថ្មីក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាអន្តរជាតិ។

ភាពជាអ្នកដឹកនាំនិងភាពជាម្ចាស់នៃតួអង្គពាក់ព័ន្ធ ជាមួយនឹងការរួមវិភាគទានផ្នែកចំណេះដឹងដ៏មានតម្លៃពីដៃគូអភិវឌ្ឍគឺជាកត្តាគន្លឹះក្នុងការធានាឱ្យបានជោគជ័យនៃការកែទម្រង់ប្រព័ន្ធថវិកា។លើសពីនេះការគាំទ្រយ៉ាងមុតមាំនិងការណែនាំជាប្រចាំពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលជាអគ្គមេបញ្ជាការតែមួយធ្លាប់បានធ្វើឱ្យការកែទម្រង់ហិរញ្ញវត្ថុសាធារណៈទទួលបានជោគជ័យគួរជាទីមោទនៈ និងកំពុងបន្តមានសន្ទុះទៅមុខជាកត្តាមិនអាចខ្វះបាន ដើម្បីផ្តល់ក្តីសង្ឃឹមដល់កម្ពុជាក្នុងការកែទម្រង់ប្រព័ន្ធថវិកា ប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព ឆ្ពោះទៅសម្រេចគោលដៅឆ្នាំ២០២៥ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ។

## អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងបទបង្ហាញស្តីពីកំណែទម្រង់រដ្ឋបាលថ្នាក់ជាតិវិស័យថវិកាខាងលើយើងខ្ញុំទាំងពីរនាក់ពិតជាមានសេចក្តីរំភើបរីករាយជាខ្លាំង ដោយបានស្វែងយល់នូវចំណុចនីមួយៗនៃប្រធានបទខាងលើព្រោះយើងសង្កេតឃើញថា រដ្ឋាភិបាលកម្ពុជាពិតជាយកចិត្តទុកដាក់ជាខ្លាំងចំពោះថវិកាជាតិក៏ដូចជាប្រជាជនកម្ពុជា ទោះបីជាប្រទេសជាតិស្ថិតនៅក្នុងស្ថានភាពដ៏លំបាកមួយក៏ដោយក៏រាជរដ្ឋាភិបាលខិតខំប្រឹងប្រែងរិះរកគ្រប់មធ្យោបាយដើម្បីដោះស្រាយបញ្ហា ដើម្បីកុំឱ្យប្រទេសជាតិស្ថិតក្នុងស្ថានការណ៍ដែលប្រឈមនឹងបញ្ហាហិរញ្ញវត្ថុធ្ងន់ធ្ងរ។ តួយ៉ាងដូចដែលបានបង្ហាញជូនខាងលើគឺក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជាក្បាលម៉ាស៊ីនយ៉ាងសំខាន់នៅក្នុងការចាត់ចែង គ្រប់គ្រង រៀបចំបែងចែងប្រព័ន្ធថវិកាទៅតាមក្រសួងស្ថាប័ននៅកម្ពុជាទាំងអស់បានអនុម័តនូវច្បាប់ហិរញ្ញវត្ថុជារៀងរាល់ឆ្នាំយ៉ាងល្អិតល្អន់ ដើម្បីឱ្យចំណូល និងចំណាយមានភាពសមា

មាត្រនឹងគ្នាដើម្បីឱ្យសេដ្ឋកិច្ចរបស់ប្រទេសមានភាពរីកចម្រើន ក៏ប៉ុន្តែដោយសារតែរយៈពេលពីរឆ្នាំចុងក្រោយនេះប្រទេសកម្ពុជាក៏បានជួបនូវវិបត្តសេដ្ឋកិច្ចដែលបង្កឡើងដោយវីរុសកូវីដ-១៩ ទើបធ្វើឲ្យរដ្ឋាភិបាលក៏ដូចជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែមានផែនការថ្មីៗ ដើម្បីទប់ទល់នឹងស្ថានភាពបែបនេះ។

ក្នុងនោះដែរចំពោះយុទ្ធសាស្ត្រនៃការកែទម្រង់រដ្ឋបាលថ្នាក់ជាតិវិស័យថវិកា បានឆ្លុះបញ្ចាំងអំពីលទ្ធផល និងប្រសិទ្ធិភាពនៃការកៀរគរចំណូលតាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ជាពិសេសការលើកកម្ពស់វប្បធម៌បង់ពន្ធ ការបង្ក្រាបអំពើរត់ពន្ធ និងការគេចវេសពន្ធគ្រប់រូបភាពឲ្យដល់ឫសគល់ និងការកែលម្អអភិបាលកិច្ចក្នុងការប្រមូលចំណូល ព្រមទាំងប្រសិទ្ធភាពនៃប្រតិបត្តការចំណាយតាមរយៈការតម្រង់ការចាយឱ្យចំមុខ និងមិនខ្ជះខ្ជាយដែលធ្វើឱ្យរដ្ឋាភិបាលមានលទ្ធភាពឆ្លើយតបបានកាន់តែមានប្រសិទ្ធភាពទៅនឹងបណ្តាតម្រូវការជាអាទិភាពនានាជាពិសេសការអនុវត្តក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២០ ដែលត្រូវបានរៀបចំឡើងស្របតាមអាទិភាពគោលនយោបាយ។

បន្ថែមពីលើនេះទៀតដោយមើលឃើញពីលទ្ធផលជាក់ស្តែង និងការរីកចម្រើនក្រោយពីការធ្វើកំណែទម្រង់នេះយើងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលដែលបានដាក់ចេញនូវយុទ្ធសាស្ត្រថ្មីៗនៅក្នុងការបត់បែនទៅតាមស្ថានការណ៍មិនថាកាលៈទេសៈនៃការរីករាលដាលជម្ងឺកូវី-១៩នេះ ឬក៏ស្ថានការណ៍ផ្សេងៗទៀតដោយធ្វើយ៉ាងណាមិនឱ្យប្រជាជនមានទុក្ខលំបាកខ្លាំង ហើយបានជួយសម្របសម្រួលដល់ជីវភាពប្រជាជនដើម្បីឲ្យឆ្លងកាត់គ្រប់ស្ថានការណ៍។

# ឯកសារយោង

**+ ឯកសារយោងមានលក្ខណៈជាច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត**

- ប្រកាសស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)ឆ្នាំ២០១៧
- ច្បាប់ថវិកាឆ្នាំ២០១០
- ច្បាប់ និងបទបញ្ញតិថវិកា ឆ្នាំ២០២១
- ច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២១
- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨
- ច្បាប់កែតម្រូវហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ជាតិ

**+ ឯកសារមានលក្ខណៈគោលនយោបាយ**

- ទស្សនទាន ស្តីអំពីទិសដៅយុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា២០១៣-២០២០
- យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥
- ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៧-២០១៩

+ **ឯកសារណែនាំ**

- សារាចរណ៍ណែនាំស្តីពី ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ២០២១
- សារាចរណ៍ណែនាំស្តីពីការធ្វើវិចារណកម្មនិងពង្រឹងប្រសិទ្ធភាពថវិកាថ្នាក់ជាតិសម្រាប់អនុវត្ត
- ចក្ខុវិស័យ និងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងថវិកាឆ្នាំ២០១៦
- គោលការណ៍ណែនាំបន្ថែមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៩-២០៣០

+ **ឯកសារជាសៀវភៅ**

- សម្តេចព្រះសង្ឃរាជ ជួន ណាត វចនានុក្រមខ្មែរ

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១៖** ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រមក/០៦១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ សារាចរណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រឆ្នាំ២០២២-២០២៥

**ឧបសម្ព័ន្ធទី២៖** ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ សារាចរណ៍ណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១

**ឧបសម្ព័ន្ធទី៣៖** ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៨ សារាចរណ៍ណែនាំស្តីពីការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយថវិកាថ្នាក់ជាតិ សម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៣ ស.ណន

**សារាចរណែនាំ**

**ស្តីពី**

**ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២២-២០២៤**

## ១-សេចក្តីផ្តើម

មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០០៨ បានចែងថា ប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ចែកជា ៣ ដំណាក់កាល៖ **ដំណាក់កាលទី ១** គឺការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចាប់ពីខែ មីនា ដល់ខែ ឧសភា, **ដំណាក់កាលទី ២** គឺការរៀបចំកញ្ចប់ថវិកា ចាប់ពីខែ មិថុនា ដល់ខែ កញ្ញា និង**ដំណាក់កាលទី ៣** គឺការអនុម័តថវិកា ចាប់ពីខែ តុលា ដល់ខែ ធ្នូ។ សម្រាប់ដំណាក់កាលទី ១ នេះ រាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ចេញរួចហើយនូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ដើម្បីឱ្យក្រសួង-ស្ថាប័នសាមីនីមួយៗមានមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២២-២០២៤។ ក្នុងន័យនេះ សម្រាប់ជំហានបន្ទាប់នៃដំណាក់កាលទី ១, រាជរដ្ឋាភិបាលត្រូវដាក់ចេញនូវសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២២-២០២៤ ដើម្បីផ្តល់គោលការណ៍ណែនាំថ្មីៗ និងមគ្គុទ្ទេសបច្ចេកទេសគន្លឹះៗ សម្រាប់គ្រប់ក្រសួង-ស្ថាប័នធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រថវិកា ដែលជា ផែនការថវិការយៈពេល ០៣ ឆ្នាំរំកិល ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមក្រសួង-ស្ថាប័ននីមួយៗ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារដែលបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាលនិងវិស័យអប់រំ) ត្រូវរៀបចំ។ ដោយឡែកចំពោះការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងមានសារាចរណែនាំដោយឡែកមួយផ្សេងទៀត ស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១។

ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍ដ៏សំខាន់សម្រាប់៖ (១)-ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និងគោលនយោបាយរបស់រាជរដ្ឋាភិបាល, (២)-បង្កើនវិចារណកម្មអាទិភាពចំណាយឱ្យកាន់តែឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន, (៣)-ធានានិរន្តរភាពនៃការអនុវត្តកម្មវិធីរបស់ក្រសួង-ស្ថាប័ន ដើម្បីសម្រេចគោលបំណងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ (៤)-ជាមូលដ្ឋានសម្រាប់ការពន្យល់ និងការបង្ហាញសេចក្តីសំអាងអំពីតម្រូវការថវិកាសម្រាប់អនុវត្តគោលនយោបាយ និង


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ